United Nations Educational, Scientific and Cultural Organization

Sustainable Development Goals

Bangkok Office
Asia and Pacific Regional Bureau for Education

SEAMEO

# ការពង្រឹងគុណភាពសិក្សាដំបូង ភាគ១

## ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច (ECCE) សម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍



Education 2030

# ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀន
# ផ្នែកថែទាំ និងអប់រំកុមារតូច

## សម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍

បោះពុម្ពនៅឆ្នាំ២០១៨ ដោយអង្គការសហប្រជាជាតិសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ( UNESCO )
៧ Place de Fontenoy, ៧៥៣៥២ ប៉ារីស ០៧ SP សាធារណរដ្ឋបារាំង និងទីស្នាក់ការអង្គការយូណេស្កូប្រចាំទីក្រុងបាងកក និងអង្គការស៊ីមេអូ ( SEAMEO )

© UNESCO and SEAMEO 2018
ISBN 978-92-9223-585-7 (Print version)
ISBN 978-92-9223-586-4 (Electronic version)

សៀវភៅនេះអាចរកមើលបាននៅលើគេហទំព័ររបស់ Open Access ក្រោមអាជ្ញាប័ណ្ណ Attribution-ShareAlike 3.0 IGO ( CC-BY-SA 3.0 IGO ) ( http://creativecommons.org/licenses/by-sa/3.0/igo/ )។ ពេលប្រើប្រាស់ខ្លឹមសារនៅក្នុងសៀវភៅនេះ អ្នកប្រើប្រាស់យល់ព្រមទទួលយកលក្ខខណ្ឌរបស់ Open Access Repository នៃអង្គការយូណេស្កូ។ សូមចូលមើលគេហទំព័រ ( http://www.unesco.org/open-access/terms-use-ccbysa-en )។

ការប្រើប្រាស់ឈ្មោះ និងការបង្ហាញសម្ភារៈទាំងឡាយនៅក្នុងសៀវភៅនេះ មិនបានបង្ហាញអំពីទស្សនៈណាមួយ របស់អង្គការយូណេស្កូ និងអង្គការស៊ីមេអូទាក់ទងទៅនឹងតួនាទីស្របច្បាប់នៃប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឬទាក់ទងទៅនឹងការកំណត់ព្រំដែននៃខណ្ឌសីមារបស់ខ្លួនឡើយ។

គំនិត និងទស្សនៈដែលបង្ហាញនៅក្នុងសៀវភៅនេះ គឺជារបស់អ្នកនិពន្ធតែប៉ុណ្ណោះ។ គំនិត និងទស្សនៈទាំងអស់នេះមិនបង្ហាញពីគោលជំហររបស់អង្គការយូណេស្កូ និងអង្គការស៊ីមេអូ ដែលនឹងមិនមានការទទួលខុសត្រូវណាមួយឡើយ។

អ្នកសម្របសម្រួលគម្រោង៖ Kyungah Bang និង Pattama Punthawangkul
អ្នកកែសម្រួលឯកសារ៖ Sandy Barron
រូបភាពក្របមុខ៖ ©Jimmy Tran/Shutterstock.com
រចនាសៀវភៅដោយ៖ Umaporn Tang-on

TH/C3-1677/IQE/18/003-300-Rev.

# មាតិកា


សេចក្តីថ្លែងអំណរគុណ ...... vi

១- សេចក្តីផ្តើម ...... ១

គោលបំណង ...... ២

ក្រុមគោលដៅ ...... ២

២- បរិបទនៃការបង្កើតក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀន ECCE សម្រាប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ...... ៣

ការតភ្ជាប់ក្របខ័ណ្ឌសមត្ថភាពទៅនឹងស្តង់ដារដែលមានស្រាប់ ...... ៦

៣- ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនអប់រំ និងថែទាំកុមារតូចសម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍ ...... ៨

ទិដ្ឋភាពបរិបទរួមសម្រាប់ក្របខ័ណ្ឌមសត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ...... ៩

ការយល់ដឹងពីសមាសភាគនៃក្របខ័ណ្ឌ ...... ១២

៤- ការប្រើប្រាស់ និងកម្មវិធីដែលអាចធ្វើបាន ...... ២៦

៥- ផ្លូវឆ្ពោះទៅមុខ ...... ៣១

ឯកសារយោង ...... ៣២

សទ្ទានុក្រមនៃពាក្យគន្លឹះ និងនិយមន័យសំខាន់ៗ ...... ៣៣


## បញ្ជីនៃតារាង រូបភាព និងប្រអប់


តារាងទី១. សូចនាករដែលបានជ្រើសរើសសម្រាប់ការអប់រំកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ ...... ៣

តារាងទី២. គំរូនៃការប្រើប្រាស់ និងការអនុវត្តក្របខ័ណ្ឌសមត្ថភាពថែទាំ និងអប់រំកុមារតូច ...... ២៧

រូបភាពទី១. អត្រាសិស្សជាមធ្យមសម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិក្នុងការអប់រំកុមារតូច (headcount basis, 2015) ...... ៤

រូបភាពទី២. ដំណើរការគ្រប់គ្រង និងអភិវឌ្ឍគ្រូបង្រៀន ...... ៦

រូបភាពទី៣. ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចសម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍ ...... ៩

ប្រអប់ទី១. សមត្ថភាពជំនាញគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចលើចំណេះដឹងខ្លឹមសារ ប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ ...... ១៥

ប្រអប់ ២. សមត្ថភាពរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ECCE ក្នុងដែនកំណត់បរិយាកាសនៃការសិក្សា ...... ១៩

ប្រអប់ ៣. សមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងដែនកំណត់នៃការចូលរួម និងសហការ ...... ២១

ប្រអប់ទី៤. សមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ...... ២៤

# សេចក្តីថ្លែងអំណរគុណ

ការបង្កើត និងចងក្រងក្របខ័ណ្ឌ "ការថែទាំ និងការអប់រំកុមារតូច (ECCE) ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនសម្រាប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ (SEA)" នេះឡើង គឺជាការផ្តួចផ្តើមរួមគ្នារបស់ការិយាល័យតំបន់អាស៊ីប៉ាស៊ីហ្វិកនៃអង្គការយូណេស្កូសម្រាប់ការអប់រំ (អង្គការយូណេស្កូប្រចាំទីក្រុងបាងកក) និងលេខាធិការដ្ឋាននៃអង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍។ ក្របខ័ណ្ឌនេះ ជាផ្នែកមួយនៃគម្រោងការអភិវឌ្ឍសមត្ថភាពក្របខ័ណ្ឌគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ និងប្រទេសកំពុងអភិវឌ្ឍប្រជុំកោះតូចៗតំបន់អាស៊ីប៉ាស៊ីហ្វិករបស់អង្គការយូណេស្កូប្រចាំទីក្រុងបាងកក ដែលគាំទ្រដោយក្រសួងអប់រំនៃប្រទេសម៉ាឡេស៊ី។

អង្គការយូណេស្កូប្រចាំទីក្រុងបាងកក និងលេខាធិការដ្ឋានស៊ីមេអូ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ Philip J. Purnell, Sherlyne A. Almonte-Acosta, May Flor Pagasa Quiñones និង Merjielyn C. Emia នៃមជ្ឈមណ្ឌលស៊ីមេអូ INNOTECH ចំពោះកិច្ចខិតខំប្រឹងប្រែងដោយមិនគិតពីការនឿយហត់ក្នុងការបង្កើត និងបញ្ចប់ក្របខ័ណ្ឌនេះ។

តំណាងប្រទេសស៊ីមេអូ និងអ្នកជំនាញដូចជា Monisha Diwan, Tinsiri Siribodhi, Julia Kim, Saisuree Jutikul, Thipsuda Sumetseni និង Sujaree Suang-tho ដែលបានចូលរួមក្នុងសិក្ខាសាលាអនុតំបន់ស្តីពីការអភិវឌ្ឍគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ កាលពីថ្ងៃទី១-៩ ខែសីហា ឆ្នាំ២០១៧ ក្នុងទីក្រុងបាងកក ព្រះរាជាណាចក្រថៃ បានចូលរួមចំណែកយ៉ាងធំធេងក្នុងការបង្កើតក្របខ័ណ្ឌនេះឡើង។

សេចក្តីព្រាងនៃក្របខ័ណ្ឌនេះ ត្រូវបានពិនិត្យជាដំណាក់កាលខុសៗគ្នាដោយក្រុមទីប្រឹក្សាគម្រោង ដែលរួមមានអ្នកជំនាញលើផ្នែកថែទាំ និងអប់រំកុមារតូច៖ Yoshie Kaga, Mami Umayahara, Sheldon Shaeffer, Mugyeong Moon, Glen Palmer, Noraini binti Idris, និង Ufemia Camaitaoga។ យើងខ្ញុំក៏សូមថ្លែងអំណរគុណដល់សមាជិកក្រុមទីប្រឹក្សាសម្រាប់ការណែនាំ និងដំបូន្មានជាបន្តបន្ទាប់ចាប់តាំងពីដើមរហូតដល់ចប់។

គម្រោងនេះ គ្រប់គ្រង និងសម្របសម្រួលដោយគម្រោងរបស់អង្គការយូណេស្កូប្រចាំទីក្រុងបាងកក ដែលរួមមាន៖ Maki Hayashikawa, Kyungah Bang, Mun Yee Lee និង Ricelie Maria Gesuden ព្រមទាំង Agnes P Valenzuela និង Pattama Punthawangkul មកពីលេខាធិការដ្ឋានស៊ីមេអូ។

# ១- សេចក្តីផ្តើម

ផ្អែកលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ ដែលជាវេទិកាមួយក្នុងការសម្រេចឱ្យបាននូវផលសម្រេចនៃការថែទាំ និងអប់រំកុមារតូចប្រកបដោយគុណភាពនៅឆ្នាំ២០៣០ អ្នករៀបចំគោលនយោបាយថែទាំនិងអប់រំកុមារតូច (ECCE) អ្នកប្រតិបត្តិ និងអ្នកសិក្សាមកពីប្រទេសអាស៊ីប៉ាស៊ីហ្វិក បានជួបជុំគ្នាក្នុងវេទិកាគោលនយោបាយតំបន់អាស៊ីប៉ាស៊ីហ្វិកលើកទី២ ស្តីពីការថែទាំ និងអប់រំកុមារតូចដែលបានធ្វើឡើងនៅទីក្រុង Putrajaya ក្នុងឆ្នាំ២០១៦ ដើម្បីចែករំលែកបទពិសោធន៍ នវានុវត្តន៍ និងមេរៀនពិសោធន៍ក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយ និងគំនិតផ្តួចផ្តើមស្តីពីការថែទាំ និងអប់រំកុមារតូច។

នៅចុងបញ្ចប់នៃវេទិកានេះ តាមរយៈសេចក្តីថ្លែងការណ៍ទីក្រុង Putrajaya អ្នកចូលរួមបានបង្ហាញអំពីការប្តេជ្ញាចិត្តរួមគ្នាចំពោះកិច្ចការថែទាំនិងអប់រំកុមារតូច (ECCE)។ ក្របខ័ណ្ឌសកម្មភាពទាំងប្រាំបួនចំណុច ត្រូវបានគូសបញ្ជាក់ ដើម្បីគាំទ្រសមិទ្ធផលនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ៤.២ "នៅឆ្នាំ២០៣០ ដែលធានាថាកុមារាកុមារីទាំងអស់ទទួលបានការអភិវឌ្ឍ ថែទាំ និងអប់រំនៅកម្រិតមត្តេយ្យសិក្សាប្រកបដោយគុណភាព ដើម្បីឱ្យពួកគេត្រៀមខ្លួនរួចរាល់សម្រាប់ការអប់រំនៅបឋមសិក្សា"។ ជាមួយគ្នានេះដែរ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ៤.២ ទទួលស្គាល់នូវតម្រូវការក្នុងការបង្កើនការផ្គត់ផ្គង់គ្រូបង្រៀនដែលមានសមត្ថភាពតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការបណ្តុះបណ្តាលគ្រូក្នុងប្រទេសកំពុងអភិវឌ្ឍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចតួច និងប្រទេសប្រជុំកោះតូចៗ ដែលកំពុងអភិវឌ្ឍ (អង្គការសហប្រជាជាតិ ២០១៥)។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការសកល ព្រមទាំងដើម្បីទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់គ្រូបង្រៀនក្នុងការអភិវឌ្ឍកុមារតូច អង្គការយូណេស្កូបានចូលរួមក្នុងការផ្តួចផ្តើមនៅផ្នែកផ្សេងៗនៃពិភពលោក ដើម្បីរួមចំណែកអភិវឌ្ឍវិជ្ជាជីវៈ និងកសាងសមត្ថភាពគ្រូផ្នែកថែទាំ និងអប់រំកុមារតូច ដោយមានការដាក់បញ្ចូលនូវការអភិវឌ្ឍក្របខ័ណ្ឌសមត្ថភាពសម្រាប់គ្រូផ្នែកនេះនៅតាមប្រទេសតំបន់អាស៊ីអាគ្នេយ៍។ ក្របខ័ណ្ឌនេះ ត្រូវបានរៀបចំឡើងដោយមានការចូលរួម ពិគ្រោះយោបល់ និងបញ្ចេញនូវទស្សនៈគំនិតផ្សេងៗពីសំណាក់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ក្រុមអ្នកស្រាវជ្រាវ និងអ្នកប្រតិបត្តិមកពីប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។

ផ្នែកទី១ ឯកសារនេះផ្តល់និងពិភាក្សាអំពីខ្លឹមសារសង្ខេប គោលបំណង និងក្រុមគោលដៅផ្អែកលើក្របខ័ណ្ឌដែលត្រូវបានរៀបចំឡើង។ ផ្នែកទី២ ឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃក្របខ័ណ្ឌថែទាំ និងអប់រំកុមារតូច (ECCE) កម្រិតតំបន់មុននឹងបន្តចូលផ្នែកទី៣ ដែលពិភាក្សាលើក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនសម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍។ ផ្នែកទី៤ លើកឡើងអំពីការប្រើប្រាស់ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀន និងផ្នែកចុងក្រោយ សន្និដ្ឋានផ្អែកលើទិដ្ឋភាពនានាសម្រាប់សកម្មភាពនាពេលអនាគត់។

## គោលបំណង

ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច មានគោលបំណងពង្រឹងការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈគ្រូបង្រៀនផ្នែកនេះក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ដោយផ្អែកលើការរៀបចំ ការផ្ដួចផ្ដើមកម្រិតតំបន់ ដែលមានស្រាប់ស្ដីពីក្របខ័ណ្ឌ និង ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច (ECCE) ដូចខាងក្រោម៖

- ផ្ដល់នូវការពិពណ៌នាគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងចំណេះដឹង ជំនាញ និងឥរិយាបថ ដែលគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ត្រូវការ ដើម្បីគាំទ្រដល់ការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារតូច។
- ផ្ដល់នូវខ្លឹមសារ ដែលមានទម្រង់ស៊ីចង្វាក់គ្នា និងមានភាពប្រទាក់ក្រឡា ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកផ្នែកអប់រំកុមារតូចនៃប្រទេសតំបន់អាស៊ីអាគ្នេយ៍។
- ពង្រឹងក្របខ័ណ្ឌប្រទេសតំបន់អាស៊ីអាគ្នេយ៍ដែលមានស្រាប់ ឬដើរតួនាទីជាកត្តាលិករជំរុញឱ្យប្រទេសផ្សេងទៀតអាចអភិវឌ្ឍក្របខ័ណ្ឌគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចដាច់ដោយឡែកទៅតាមលក្ខខណ្ឌនិងទិដ្ឋភាពនៃប្រទេសរបស់ខ្លួន។
- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធផ្សេងៗ នៃក្របខ័ណ្ឌគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចកម្រិតមូលដ្ឋាន ជាតិ និងកម្រិតតំបន់។

ក្របខ័ណ្ឌគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនេះ មិនមានគោលបំណងដើម្បីជំនួសឱ្យក្របខ័ណ្ឌសមត្ថភាពគ្រូដែលមានស្រាប់ និងស្តង់ដារគ្រូបង្រៀនដែលត្រូវបានបង្កើតឡើងដោយប្រទេសតំបន់អាស៊ីអាគ្នេយ៍ ឬប្រទេសណាមួយនោះឡើយ។ ក្របខ័ណ្ឌនេះមានគោលបំណងផ្សារភ្ជាប់ការខិតខំប្រឹងប្រែងផ្សេងៗ លើកិច្ចការអប់រំកុមារតូចដើម្បីពង្រឹងគុណភាពទូទៅនៃវិស័យជាក់លាក់ណាមួយក្នុងតំបន់។ ក្របខ័ណ្ឌនេះ ត្រូវបានរៀបចំឡើងដើម្បីបន្សុីយន្តការជានាគុណភាពគ្រូឱ្យមានការឆ្លើយតបកាន់តែប្រសើរជាងមុនទៅនឹងបរិបទ និងតម្រូវការជាក់ស្ដែងនៃប្រទេសតំបន់អាស៊ីអាគ្នេយ៍។

## ក្រុមគោលដៅ

ក្របខ័ណ្ឌនេះ គ្របដណ្ដប់លើសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលបង្រៀនសិស្សចាប់ពីអាយុ ៣ឆ្នាំដល់ ៥ឆ្នាំក្នុងសាលាមត្តេយ្យសិក្សា។ ឯកសារនេះ ត្រូវបានបង្កើតឡើង សម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច និងអ្នកដែលទទួលបន្ទុកការអភិវឌ្ឍវិជ្ជាជីវៈ ដូចជាស្ថាប័នអប់រំគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា ផ្នែកអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋ និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ដែលផ្ដល់សេវាថែទាំ និង អប់រំកុមារតូច។ ផ្នែកបន្ទាប់ (ផ្នែកទី៤) បង្ហាញពីការប្រើប្រាស់ និងការអនុវត្តនៃក្របខ័ណ្ឌនេះ។

## ២- បរិបទនៃការបង្កើតក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច សម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍

ទិន្នន័យមួយចំនួន បង្ហាញថាកុមារជាទូទៅបានចូលរៀនក្នុងកម្មវិធីអប់រំកម្រិតមត្តេយ្យសិក្សានៅអាយុ៣ឆ្នាំ និងបឋមសិក្សានៅអាយុ៦ឆ្នាំនៅក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ភាគច្រើន។ គេអាចសន្មតថា កុមាររៀននៅមត្តេយ្យសិក្សាមានរយៈពេល១ឆ្នាំដល់៣ឆ្នាំ ហើយរយៈពេលដ៏សំខាន់នេះ ផ្ដល់ឱ្យគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនូវឱកាស ដើម្បីធ្វើឱ្យលទ្ធផលសិក្សា និងការអភិវឌ្ឍរបស់កុមារតូចមានភាពល្អប្រសើរឡើង និងរៀបចំពួកគេជាស្រេចសម្រាប់ការអប់រំនៅបឋមសិក្សា។

យោងតាមទិន្នន័យចុងក្រោយបង្អស់បានបង្ហាញថា ទោះបីជាមានការកើនឡើងនូវការយល់ដឹងអំពីសារៈសំខាន់នៃការថែទាំ និងអប់រំកុមារតូចក៏ដោយ ក៏លទ្ធភាពនៃការទទួលបានការអប់រំនៅកម្រិតមត្តេយ្យសិក្សាក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍នៅតែស្ថិតនៅក្រោមចំណុចដៅសម្រាប់ឆ្នាំ២០៣០ ដោយមានតែប្រទេសម៉ាឡេស៊ី និងប្រទេសវៀតណាមទេ ដែលមានអត្រាចូលរៀនយ៉ាងហោចណាស់ ៨០ ភាគរយ។

តារាងទី១. សូចនាករដែលបានជ្រើសរើសសម្រាប់ការអប់រំកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍

| ប្រទេស/ សូចនាករ | អាយុចូលរៀននៅមត្តេយ្យសិក្សា (២០១៥) | អាយុផ្លូវការចូលរៀននៅបឋមសិក្សា (២០១៥) | អំឡុងពេលសិក្សាទ្រឹស្ដីនៅមត្តេយ្យសិក្សា (២០១៥) | ការចូលរៀននៅមត្តេយ្យសិក្សា (២០១៥) | អត្រាពិតនៃការចូលរៀន (២០១៥) | អត្រារួមនៃការចូលរៀន |
|---|---|---|---|---|---|---|
| ព្រុយណេ | ៣ | ៦ | ៣ | ១៣ ៣០១ | ៦៥ | គ្មាន |
| កម្ពុជា | ៣ | ៦ | ៣ | ១៨៧ ៤៥០ | ១៧ | ៨ |
| ឥណ្ឌូនេស៊ី | ៥ | ៧ | ២ | ៥ ៣៤៩ ០៤០ | ៣៩ | ១៨ |
| ឡាវ | ៣ | ៦ | ៣ | ១៧៥ ៤៩២ | ៣៣ | គ្មាន |
| ម៉ាឡេស៊ី | ៤ | ៦ | ២ | ៩៣៤ ៤៨០ | ៨១ | គ្មាន |
| ភូមា | ៣ | ៥ | ២ | ៤៥៣ ៤៨០ | ២៤ | គ្មាន |
| ហ្វីលីពីន | ៥ | ៦ | ១ | ១ ១៦៥ ៧៧១ | ៤១ | គ្មាន |
| សឹង្ហបុរី | ៤ * | ៧ * | ៣ | ៦៦ ៣៣១ * | គ្មាន | គ្មាន |
| ថៃ | ៣ | ៦ | ៣ | ១ ៦៣៦ ២៤៤ | ៥៨ | ៧០ |
| ទីម័រខាងកើត | ៣ | ៦ | ៣ | ១៨ ៩៨៣ | ១៦ | គ្មាន |
| វៀតណាម | ៣ | ៦ | ៣ | ៣ ៧៥៤ ៩៧៥ | ៧៨ | ២១ |

***សម្គាល់៖*** *សម្រាប់ប្រទេសឥណ្ឌូនេស៊ី និងភូមាសំដៅលើឆ្នាំ២០១៤ សម្រាប់ប្រទេសវៀតណាម សំដៅលើឆ្នាំ២០១៣ សម្រាប់ប្រទេសហ្វីលីពីនសំដៅលើឆ្នាំ២០០៩។ សម្រាប់ទិន្នន័យអត្រារួមនៃការចូលរៀន (GER) សម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១២ សម្រាប់ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ២០១៤ សម្រាប់ប្រទេសថៃ និងវៀតណាម ឆ្នាំ២០១៥។*

***ប្រភព៖*** *វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ វាយតម្លៃក្នុងខែកក្កដា ឆ្នាំ២០១៧។*

**សម្រាប់ប្រទេសសឹង្ហបុរី ទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាពរួចត្រូវបានផ្ដល់ជូនដោយភ្នាក់ងារអភិវឌ្ឍកុមារតូចសឹង្ហបុរី (ECDA) ដោយមានឯកសារយោងពីស្ថិតិឯកសារប្រចាំឆ្នាំ។*

ជាមួយគ្នានេះដែរ ទិន្នន័យប្រៀបធៀបខាងលើស្តីពីគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនៅតាមប្រទេសតំបន់អាស៊ីអាគ្នេយ៍នេះ គាំទ្រតម្រូវការដើម្បីពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនបន្ថែម។ តាមទិន្នន័យបង្ហាញឱ្យឃើញថាប្រទេសព្រុយណេ កម្ពុជា ម៉ាឡេស៊ី និងវៀតណាម បានរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់គ្រូផ្នែកអប់រំកុមារតូចទាំងអស់ ឬស្ទើរតែទាំងអស់ (UIS, 2017) និងបានបង្ហាញអំពីអត្រាផលធៀបសិស្ស-គ្រូដែលមានគុណវុឌ្ឍិផ្នែកអប់រំកុមារតូចនៅមានកម្រិតទាបនៅឡើយ ហើយក៏បានផ្តល់នូវកត្តាជំរុញបន្ថែមក្នុងការបង្កើនចំនួនគ្រូបង្រៀនមានគុណវុឌ្ឍិ។

រូបភាព ១. ចំនួនសិស្សជាមធ្យមសម្រាប់គ្រូបង្រៀនដែលមានគុណវុឌ្ឍិក្នុងការអប់រំកុមារតូច (headcount basis, 2015)




*ប្រភព៖ វិទ្យាស្ថានស្ថិតិនៃអង្គការយូណេស្កូ វាយតម្លៃក្នុងខែកក្កដា ឆ្នាំ២០១៧។*

គំនិតផ្តួចផ្តើមផ្សេងៗ ដើម្បីគាំទ្រក្របខ័ណ្ឌការថែទាំ និងអប់រំកុមារតូច ត្រូវបានបង្កើតឡើងក្នុងគោលបំណងដោះស្រាយនូវគម្លាតក្នុងការអប់រំកុមារតូច។ ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព SDGs អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ (SEAMEO) ចាត់ទុកការថែទាំ និងអប់រំកុមារតូច ជាវិស័យអាទិភាពទីមួយក្នុងចំណោមវិស័យទាំង៧ ដែលត្រូវបានលើកស្ទួយចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣៥។ ដើម្បីគាំទ្រចំពោះវិស័យអាទិភាពនេះ មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការថែទាំ អប់រំកុមារតូច និងការចិញ្ចឹមបីបាច់ (SEAMEO CECCEP) ត្រូវបានបង្កើតឡើងនៅទីក្រុង Bandung ប្រទេសឥណ្ឌូនេស៊ីក្នុងឆ្នាំ២០១៧ សម្រាប់ពង្រឹងការថែទាំ និងអប់រំកុមារតូចបន្ថែមនៅតាមប្រទេសតំបន់អាស៊ីអាគ្នេយ៍តាមរយៈការកសាងសមត្ថភាព ស្រាវជ្រាវលើការគាំទ្រផ្នែកគោលនយោបាយ និងសកម្មភាពផ្សព្វផ្សាយចំណេះដឹង។

ការពិនិត្យឡើងវិញនូវគំនិតផ្តួចផ្តើមដែលផ្តោតលើការធានាគុណភាពជុំវិញការគាំពារ និងអភិវឌ្ឍ (ECCD)[1] ត្រូវបានធ្វើឡើងក្នុងប្រទេសអាស៊ីអាគ្នេយ៍ទាំង១០[2] ដែលបានគូសបញ្ជាក់ថាប្រទេសនីមួយៗ សម្រេចលទ្ធផលក្នុងកម្រិតផ្សេងៗគ្នាក្នុងកិច្ចការអភិវឌ្ឍប្រព័ន្ធធានាគុណភាព។ ឧទាហរណ៍ ប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីគឺស្ថិតក្នុងចំណោមប្រទេស ដែលមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការអភិវឌ្ឍប្រព័ន្ធធានាគុណភាព ខណៈពេលដែលប្រទេសហ្វីលីពីន និងព្រុយណេស្ថិតក្នុងចំណោមប្រទេសដែលកំពុងអភិវឌ្ឍ និងបានអនុវត្តជាបណ្តើរៗនូវប្រព័ន្ធធានាគុណភាពស្របពេលជាមួយគ្នានៃការអភិវឌ្ឍក្របខ័ណ្ឌនេះឡើង។ ប្រទេសថៃមានគោលនយោបាយទាក់ទងនឹងការធានាគុណភាព ដោយ

(1) ការប្រើប្រាស់ពាក្យ “ECCD” ឆ្លុះបញ្ចាំងពីចំណុចស្នូលនៃកម្មវិធីដែលផ្តោតលើការអភិវឌ្ឍ និងថែទាំកុមារតូច (ឆ្នាំ២០១០ ដល់ឆ្នាំ២០១១)។

(2) ដោយសារតែប្រទេសសឹង្ហបុរីមិនអាចចូលរួមក្នុងសិក្ខាសាលានេះបាន ដើម្បីឱ្យទិន្នន័យនេះពេញលេញគម្រោង INNOTECH- ARNEC មានគោលបំណងរួមបញ្ចូលទិន្នន័យស្តីពីការអភិវឌ្ឍ និងការថែទាំកុមារតូចក្នុងប្រទេសសិង្ហបុរី។

បានបញ្ចូលទាំងគោលនយោបាយ ដែលបានបញ្ជ្រាបចូលក្នុងច្បាប់អប់រំជាតិឆ្នាំ១៩៩៩ និងក៏បានដាក់បញ្ចូលគោលនយោបាយជាក់លាក់ទៅក្នុងស្តង់ដារអប់រំមូលដ្ឋាន និងកុមារតូចឆ្នាំ២០០៥ (SEAMEO INNOTECH and ARNEC, n.d.)។

មុនឆ្នាំ២០១៤ ខណៈពេលដែលសហគមន៍អន្តរជាតិ កំពុងតែរៀបចំខ្លួនដើម្បីផ្លាស់ប្តូរឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព(SDGs) ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយមានការគាំទ្រពីអង្គការយូណេស្កូ អង្គការរដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍ហៅកាត់ថាស៊ីមេអូ (SEAMEO) និងមានការផ្តល់មូនិធិពីរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមអនុវត្តគម្រោង "**ការអភិវឌ្ឍគ្រូបង្រៀនកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍**"។ គម្រោងនេះ រួមចំណែកធ្វើឱ្យប្រសើរឡើងនូវការអប់រំនៅកម្រិតមត្តេយ្យសិក្សាប្រកបដោយគុណភាព ដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព និងវិជ្ជាជីវៈគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ គម្រោងនេះ ចាំបាច់ត្រូវធ្វើការស្ទង់មតិក្នុងចំណោមរដ្ឋមន្ត្រីអប់រំទាំង១១ប្រទេស និងតាមរយៈសិក្ខាសាលាពិគ្រោះយោបល់ជាបន្តបន្ទាប់ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលប្រមូលបាន។ គម្រោងនេះក៏បានជំរុញឱ្យ "គោលការណ៍សម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនៅអាស៊ីអាគ្នេយ៍" លេចចេញជារូបរាងឡើង ហើយបានទទួលការឯកភាពពីរដ្ឋមន្ត្រីអប់រំនៃប្រទេសជាសមាជិកស៊ីមីអូ (UNESCO and SEAMEO, 2016)។

ដើម្បីដោះស្រាយក្តីកង្វល់របស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច សិក្ខាសាលាផ្ទៀងផ្ទាត់ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិភាក្សាអំពីគោលការណ៍ណែនាំ សម្រាប់ដាក់ចេញជាអនុសាសន៍ដ៏រឹងមាំក្នុងការជួយជ្រោមជ្រែងក្រសួងអប់រំ និងភាគីពាក់ព័ន្ធសំខាន់ៗពង្រឹង និងធ្វើឱ្យល្អប្រសើរឡើងនូវសមត្ថភាពរបស់អ្នកប្រតិបត្តិអប់រំកុមារតូច។ ដូច្នេះពួកគេនឹងក្លាយជាចលករដ៏មានប្រសិទ្ធភាពក្នុងកិច្ចការធានាគុណភាពផ្នែកថែទាំ និងអប់រំកុមារតូច។ ឧទាហរណ៍ ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការរក្សាទុក និងពង្រាយគ្រូ ប្រទេសមួយចំនួនត្រូវបានលើកទឹកចិត្តឱ្យរៀបចំយុទ្ធសាស្ត្រដាក់ពង្រាយគ្រូជាប្រព័ន្ធដើម្បីធានាថាចំនួនបុគ្គលិកអប់រំ និងអ្នកថែទាំកុមារតូចមានរបាយស្មើគ្នា និងដើម្បីធានាថា គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចមានសមត្ថភាពត្រូវបានដាក់ពង្រាយដល់តំបន់ងាយរងគ្រោះ តំបន់ក្រីក្រ និងតំបន់ដាច់ស្រយាល។ ប្រទេសទាំងនេះក៏ត្រូវបានលើកទឹកចិត្តបង្កើតគោលនយោបាយ ដើម្បីធានាការរក្សាទុកគ្រូបង្រៀនឱ្យស្ថិតក្នុងអាជីពរបស់ខ្លួនបានយូរអង្វែងផងដែរ។ ដើម្បីធានាការអភិវឌ្ឍវិជ្ជាជីវៈបន្ត ក្រសួងបានលើកទឹកចិត្តឱ្យបង្កើតដំណើរការ និងកម្មវិធីប្រកបដោយសមធម៌និងមានលក្ខណៈជាប្រព័ន្ធ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច និងអ្នកថែទាំកុមារតូច (Ibid.)។

នៅដើមឆ្នាំ២០១៧ លេខាធិការដ្ឋានស៊ីមេអូ មជ្ឈមណ្ឌលស៊ីមេអូ INNOTECH និងក្រុមប្រឹក្សាគ្រូបង្រៀននៃប្រទេសថៃ (TCT) បានចាប់ផ្តើមគម្រោងសហប្រតិបត្តិការរួមគ្នាមួយ ដើម្បីរៀបចំបង្កើតក្របខ័ណ្ឌសមត្ថភាពតំបន់សម្រាប់គ្រូបង្រៀនបឋមសិក្សា និងមធ្យមសិក្សាក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍។ ទោះបីជាក្រុមគោលដៅដែលជាគ្រូមកពីភូមិសិក្សាផ្សេងគ្នាក៏ដោយ ក៏ក្របខ័ណ្ឌនេះ ផ្តោតលើសមត្ថភាពសំខាន់ៗចំនួន៤សម្រាប់ គ្រូបង្រៀនអប់រំមូលដ្ឋានដែលរួមមាន(១) ដឹង និងយល់នូវអ្វីដែលត្រូវបង្រៀន (២) យុទ្ធសាស្ត្រជួយសិស្សឱ្យខិតខំរៀនសូត្រ (៣) ការងារសហគមន៍ និង (៤) តួនាទី និងភារកិច្ចដើម្បីក្លាយជាគ្រូបង្រៀនល្អ។ ក្របខ័ណ្ឌនេះជាគោលការណ៍ស្នូលដែលផ្តោតលើអ្នកសិក្សា ដោយមានការបរិយាយអំពីកត្តាធ្វើឱ្យជោគជ័យសម្រាប់អ្នកប្រើប្រាស់ដែលជាគ្រូបឋមសិក្សា អាចតាមដានវឌ្ឍនភាពនិងការវិវត្តវិជ្ជាជីវៈរបស់ខ្លួន នៅពេលពួកគេត្រួសត្រាយផ្លូវសម្រាប់សិស្សក្នុងការស្វែងរកអនាគតថ្មី និងការប្រកួតប្រជែង។ នៅពេលដែលមានការឯកភាពដោយប្រទេសជាសមាជិកស៊ីមេអូ ក្របខ័ណ្ឌសមត្ថភាពនេះនឹងត្រូវបានប្រើប្រាស់ ដើម្បីជានាំនូវគំនិតផ្តួចផ្តើមក្នុងការបន្ត និងបំពេញបន្ថែមការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំចាប់ពីគ្រូមត្តេយ្យសិក្សា

បឋមសិក្សា រហូតដល់ មធ្យមសិក្សា។

## ការភ្ជាប់ក្របខ័ណ្ឌសមត្ថភាពទៅនឹងស្តង់ដារដែលមានស្រាប់

គោលការណ៍សមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ បានអនុម័តដោយប្រទេសជាសមាជិកស៊ីមេអូ ផ្តល់ជាឯកសារធនធានដ៏មានតម្លៃសម្រាប់ក្រសួងអប់រំ ក្រសួងផ្សេងៗទៀត និងអង្គការមួយចំនួន ដែលធ្វើការងារថែទាំ និងអប់រំកុមារតូច ដើម្បីធ្វើឱ្យអាជីពរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចកាន់តែប្រសើរឡើង ជំរុញស្ថានភាព និងផ្តល់លក្ខខណ្ឌការងារសម្រាប់បុគ្គលិកថែទាំ និងអប់រំកុមារតូចឱ្យមានភាពល្អប្រសើរឡើង ស្របតាមគោលការណ៍សកលរបស់អង្គការ ILO។ គោលការណ៍នេះបានសង្ខេបពីដំណើរការអភិវឌ្ឍគ្រូបង្រៀន ដែលចាប់ផ្តើមពីការពង្រឹងគោលនយោបាយគុណវុឌ្ឍិគ្រូបង្រៀនតាមរយៈការជ្រើសរើស ការបណ្តុះបណ្តាលដំបូង ការពង្រាយ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (UNESCO and SEAMEO, 2016)។ រូបភាពទី២ បង្ហាញអំពីដំណើរការគ្រប់គ្រង និងអភិវឌ្ឍគ្រូបង្រៀន។



© Shutterstock/Namart Pieamsuwan

រូបភាពទី២ .ដំណើរការគ្រប់គ្រង និងអភិវឌ្ឍគ្រូបង្រៀន




*ប្រភព៖ អង្គការយូណេស្កូ និងអង្គការស៊ីមេអូ ២០១៦។ គោលការណ៍សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍគ្រូបង្រៀនកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍។*

គោលការណ៍នេះ ពិភាក្សាលើអនុសាសន៍ដែលបានលើកឡើងក្នុងផ្នែកសំខាន់ៗនៃការគ្រប់គ្រង និងអភិវឌ្ឍគ្រូបង្រៀនដូចខាងក្រោម៖

- គុណវុឌ្ឍិ វិញ្ញាបនបត្រ វិញ្ញាបនបត្រទទួលស្គាល់ដោយប្រព័ន្ធក្រេឌីត
- លក្ខខ័ណ្ឌជ្រើសរើសឱ្យចូលបម្រើការងារ

- កម្រិតបណ្ដុះបណ្ដាលគ្រូបង្រៀនដំបូង (វិក្រឹត្យការគ្រូបង្រៀន)
- ការដាក់ពង្រាយ និងការរក្សាទុកគ្រូបង្រៀន
- ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- សមត្ថភាព និងក្រមសីលធម៌វិជ្ជាជីវៈ
- ការពិនិត្យតាមដាន និងធានាគុណភាព សម្រាប់ការវាយតម្លៃលើការអនុវត្តការងារ
- ស្ថានភាព និងបរិស្ថានការងារ
- ប្រព័ន្ធអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពលើផ្នែកថែទាំ និងអប់រំកុមារតូច។

លើសពីនេះទៀត យោងតាមគោលការណ៍ណែនាំនៃប្រទេសតំបន់អាស៊ីអាគ្នេយ៍ បានផ្ដល់អនុសាសន៍ថា "ស្តង់ដារសមត្ថភាព គួរតែត្រូវបានធ្វើឡើងផ្អែកលើវត្ថុបំណង និងទស្សនវិស័យច្បាស់លាស់ សម្រាប់ប្រព័ន្ធអប់រំនៃប្រទេសនីមួយៗ" ហើយគួរបញ្ចូលសមត្ថភាពលើចំណេះដឹងមុខវិជ្ជាផ្សេងៗ និងខ្លឹមសារនៃកម្មវិធីសិក្សា គរុកោសល្យ ការវាស់វែងនិងការវាយតម្លៃសមត្ថភាព វប្បធម៌និងភាសា បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ ទំនាក់ទំនងបុគ្គលនិងសង្គម និងសមត្ថភាពដោះបញ្ហាបន្ទាន់ផ្សេងៗ និងក្រមសីលធម៌គ្រូបង្រៀនចំពោះកុមារ ដែលមានសារៈសំខាន់ ក្នុងការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន (UNESCO and SEAMEO, 2016: pp. 15-16) ។

ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនេះ មានការពិនិត្យ និងផ្ដល់ការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍសមត្ថភាពជំនាញដូចដែលបានលើកឡើងខាងលើ ដើម្បីធានាភាពប្រទាក់ក្រឡាគ្នាជាមួយគោលការណ៍ក្នុងតំបន់។

## ៣-ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចសម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍

ក្របខ័ណ្ឌអេកូឡូស៊ីដែលបានផ្តួចផ្តើមឡើងដោយលោក Bronfenbrenner នៅឆ្នាំ១៩៩៤ ស្តីពី**ការធ្វើឱ្យគុណភាពជីវិតកាន់តែប្រសើរ** ត្រូវបានប្រើប្រាស់ជាឯកសារយោងដ៏មានសារៈសំខាន់ក្នុងការរៀបចំក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ ក្របខ័ណ្ឌរបស់លោក Bronfenbrenner បានទទួលស្គាល់អំពីចំណុចប្រសព្វនៃកត្តាទាំងអស់ដែលរួមចំណែកលើការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ ហើយក៏បានទទួលស្គាល់ផងដែរថាការអភិវឌ្ឍរបស់កុមារមិនមែនកើតឡើងដោយឯកឯងនោះទេ។ កុមារអភិវឌ្ឍកាន់តែឆាប់រហ័សនៅពេលដែលពួកគេមានទំនាក់ទំនងយ៉ាងទៀងទាត់ និងកាន់តែទូលំទូលាយជាមួយអ្នកដទៃទៀត។ ដូច្នេះ ការប្រាស្រ័យទាក់ទងរវាងកុមារ និងគ្រូរបស់ពួកគេក្នុងសាលា និងបរិស្ថានសិក្សាផ្សេងទៀតមានសារៈសំខាន់ខ្លាំងណាស់។ ការសិក្សាស្រាវជ្រាវ ស្តីពីតួនាទីសំខាន់របស់គ្រូបង្រៀនក្នុងការអភិវឌ្ឍកុមារឱ្យទទួលបានលទ្ធផលល្អក្រោយពីបញ្ចប់ការសិក្សា បានបង្ហាញអំពីកត្តាជំរុញបន្ថែមក្នុងការពង្រឹងសមត្ថភាពជំនាញគ្រូបង្រៀននៅកម្រិតការអប់រំកុមារតូច (សូមមើលឧទាហរណ៍ Barnett 2013)។

ក្របខ័ណ្ឌនេះ បានកំណត់និយមន័យសមត្ថភាពថា ជាបណ្តុំនៃចំណេះដឹង ជំនាញ សមត្ថភាព ឥរិយាបថ និងលក្ខណៈសម្បត្តិផ្ទាល់ខ្លួន ដែលរួមចំណែកពង្រឹងភាពជោគជ័យក្នុងការបំពេញការងារក្នុងវិស័យជាក់លាក់ណាមួយ។ ក្នុងបរិបទនៃការថែរទាំ និងអប់រំកុមារតូច (ECCE) សមត្ថភាពជំនាញរបស់គ្រូពិតជាមានសារៈសំខាន់ណាស់ ដើម្បីធ្វើឱ្យសម្រេចបានលទ្ធផលរំពឹងទុកនៃការរៀនសូត្រ និងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ។ ផ្អែកលើក្របខ័ណ្ឌអេកូឡូស៊ីរបស់លោក Bronfenbrenner និងសមត្ថភាពជំនាញរបស់គ្រូដែលត្រូវបានកំណត់នៅក្នុងគោលការណែនាំរបស់អង្គការយូណេស្កូនិងអង្គការស៊ីមេអូនៅឆ្នាំ២០១៦ ព្រមទាំងទស្សនៈផ្សេងៗពីអ្នកប្រតិបត្តិនិងអ្នកជំនាញផ្នែកថែទាំនិងអប់រំកុមារតូចដែលចូលរួមក្នុងសិក្ខាសាលាផ្ទៀងផ្ទាត់ក្របខ័ណ្ឌសមត្ថភាពធ្វើឡើងនៅប្រទេសថៃកាលពីខែសីហា ឆ្នាំ២០១៧ ក្របខ័ណ្ឌសមត្ថភាពនេះ ផ្តោតជាសំខាន់ទៅលើគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលមានសមត្ថភាព និងបានកំណត់ថាគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច អាចបង្ហាញពីសមត្ថភាពជំនាញស្នូលទាំងបួន៖ (១) ចំណេះដឹងលើមុខវិជ្ជាជំនាញ ការប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ (២) បរិយាកាសសិក្សារៀនសូត្រ (៣) ការចូលរួម និងកិច្ចសហការ (៤) ការអភិវឌ្ឍវិជ្ជាជីវៈ។ ការដាក់បញ្ចូលនូវសមត្ថភាពជំនាញទាំងបួននេះ គឺជាបណ្តុំសមត្ថភាពជំនាញទូទៅ ឬសមត្ថភាពជំនាញស្នូលទាំង៧ ដែលទាក់ទងនឹងគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងការទទួលខុសត្រូវ និងគាំទ្រ ឬជំរុញទឹកចិត្ត ឬទាក់ទងនឹងចំណេះដឹង ភារកិច្ចជាក់លាក់ ដែលគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចអាចបំពេញបានសម្រាប់ការគាំទ្រសមត្ថភាពជំនាញទូទៅនីមួយៗ។

រូបភាពទី៣ បង្ហាញពីក្របខ័ណ្ឌគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចសម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍។ បញ្ជីសមត្ថភាពជំនាញគាំទ្រ និងជំរុញ ដែលជាធាតុចូលនៃក្របខ័ណ្ឌសមត្ថភាពនេះ នឹងត្រូវបានលើកយកមកពិភាក្សាក្នុងផ្នែកបន្តបន្ទាប់ទៀត។

រូបភាពទី៣ .ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចសម្រាប់ប្រទេសតំបន់អាស៊ីអាគ្នេយ៍




## ទិដ្ឋភាពរួម នៃក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច

ផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌអេកូឡូស៊ីរបស់លោក Bronfenbrenner ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចបានបង្ហាញអំពីទំនាក់ទំនងរវាងការអភិវឌ្ឍ និងការរៀនសូត្រដំបូងរបស់កុមារ កើតមានឡើងក្នុងស្ថានភាពរៀនសូត្រផ្សេងគ្នា។ ផ្អែកតាមក្របខ័ណ្ឌរបស់លោក Bronfenbrenner ការងើបឡើងនៃវណ្ណៈកណ្តាលនៅប្រទេសតំបន់អាស៊ី បាននាំមកនូវការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រួសារទៅជាប្រព័ន្ធមីក្រូ ( មើលជាឧទាហរណ៍ ADB ) ។ ឧទាហរណ៍ ជាប្រពៃណី បុរសដើរតួនាទីសំខាន់ជាអ្នករកចំណូលក្នុងគ្រួសារ ប៉ុន្តែឥឡូវស្ត្រី ក៏រួមចំណែកក្នុងការរកចំណូលបានច្រើនជាងមុនជូនដល់គ្រួសារផងដែរ។ ដោយសារឪពុកម្តាយជាអ្នករួមចំណែកក្នុងការរកចំណូលជូនដល់គ្រួសារ ទំនួលខុសត្រូវនៃការថែទាំ និងការអប់រំកុមារតូច ជាបន្ទុករបស់សមាជិកគ្រួសារផ្សេងទៀតដូចជាៈ ជីដូនជីតា បងប្អូនបង្កើត និងសមាជិកគ្រួសារផ្សេងទៀត ហើយក្នុងករណីខ្លះ ជួលអ្នកមើលថែជំនួស។

ទន្ទឹមនឹងនេះ អត្ថន័យថ្មីនៃពាក្យ "គ្រួសារ" គឺចាត់បញ្ចូលទាំងប្រភេទគ្រួសារដែលមានឪពុកឬម្តាយ ព្រមទាំងគ្រួសារដែលមានដៃគូភេទដូចគ្នា។ តាមរយៈនៃការផ្លាស់ប្តូរតថភាពនេះ ជាតុផ្សំនៃសេដ្ឋកិច្ចដូចជា ការធ្វើអន្តោប្រវេសន៍អចិន្ត្រៃយ៍ ឬតាមរដូវកាលដើម្បីស្វែងរកការងាររបស់ឪពុកម្តាយ ធ្វើឱ្យជះឥទ្ធិពលដល់ការអភិវឌ្ឍ និងការលូតលាស់របស់កូន។ តាមការសិក្សាស្រាវជ្រាវរបស់ Reye ស្តីពីបន្ទុកសង្គមលើការធ្វើអន្តោប្រវេសន៍បានសង្កត់ធ្ងន់លើ "អវត្តមាន

របស់ឪពុកម្តាយ បានបង្កើតឱ្យមានការផ្លាស់ទីលំនៅដោយបង្ខំ ការរំខាន និងការផ្លាស់ប្តូរអ្នកមើលថែ" (Reyes, 2008)។ ជារឿយៗ កុមារដែលឪពុកម្តាយទុកចោលនៅផ្ទះ ត្រូវបានចិញ្ចឹមបីបាច់ដោយសមាជិកគ្រួសារដែលមានការអប់រំតិចតួច ខ្វះការលើកទឹកចិត្ត និងខ្វះការយកចិត្តទុកដាក់។ ការផ្លាស់ប្តូរក្នុងស្ថានភាពផ្សេងៗគ្នារបស់កុមារទាំងនេះ នឹងប៉ះពាល់ដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់ពួកគេ។

ក្របខ័ណ្ឌនេះក៏ទទួលស្គាល់ផងដែរថាទិដ្ឋភាពនៃការថែទាំ និងអប់រំកុមារតូច មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ហេតុនេះហើយ ក្របខ័ណ្ឌនេះបង្ហាញពីភាពចាំចាច់ គុណភាព និង/ឬភាពមិនចាំបាច់នៃ (១) ស្ថានភាពប្រទេសជាតិ រួមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមនយោបាយ បទដ្ឋានវប្បធម៌ និងគុណតំលៃ (២) គោលនយោបាយថ្នាក់ជាតិទាក់ទងនឹងការថែទាំ និងអប់រំកុមារតូច រួមបញ្ចូលនូវស្តង់ដារសីលធម៌វិជ្ជាជីវៈសម្រាប់គ្រូផ្នែកថែទាំ និងអប់រំកុមារតូច និង (៣) ធនធានគាំទ្រសម្រាប់គ្រូផ្នែកថែទាំ និងអប់រំកុមារតូច រួមទាំងធនធានមកពីប្រភពរដ្ឋ ឯកជន និងប្រភពផ្សេងៗទៀត។



© Shutterstock/Makistoc

## ១. ស្ថានភាពថ្នាក់ជាតិ

គោលនយោបាយរដ្ឋាភិបាលជាច្រើន ជាពិសេសគោលនយោបាយសេដ្ឋកិច្ចសង្គម មានឥទ្ធិពលយ៉ាងខ្លាំង និងដោយផ្ទាល់លើវិស័យអប់រំ។ គោលនយោបាយទាំងអស់នេះ ផ្តោតលើការផ្តល់ថវិកាជាតិប្រចាំឆ្នាំសម្រាប់គាំទ្រវិស័យអប់រំ ហើយមួយផ្នែកនៃថវិកានេះ ផ្តោតលើការថែទាំ និងអប់រំកុមារតូច។ គោលនយោបាយសេដ្ឋកិច្ចដែលមានគោលដៅបង្កើតការងារធ្វើ គ្រប់គ្រងច្បាប់ការងារ និងកាត់បន្ថយនិកម្មភាព មានឥទ្ធិពលដោយផ្ទាល់ និងប្រយោលទៅលើការអនុវត្ត និងការផ្លាស់ប្តូរធនធានមនុស្សផ្នែកថែទាំ និងអប់រំកុមារតូច។ កត្តាម៉ាក្រូផ្សេងៗទៀតដូចជា បទដ្ឋានវប្បធម៌ និងជំនឿគ្រប់ប្រភេទរបស់ប្រជាជន មានឥទ្ធិពលទៅលើការអនុវត្តការថែទាំ និងអប់រំកុមារតូច។

## ២ .គោលនយោបាយអប់រំថ្នាក់ជាតិ

គោលនយោបាយអប់រំជាតិដើរតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយការអនុវត្តសកម្មភាពគាំទ្រនានា និងបង្កើតយន្តការអនុវត្តជាប្រព័ន្ធ រាប់ចាប់ពីបុគ្គលិកដល់ប្រធានស្ថាប័ន។ គោលនយោបាយនេះ គឺជាឧបករណ៍ផ្សព្វផ្សាយសម្រាប់អនុវត្តជាទូទៅផ្នែកថែទាំ និងអប់រំកុមារតូច។ គោលនយោបាយដែលកំណត់អំពីស្តង់ដារជាតិស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងគោលការណ៍ណែនាំស្តីពីគុណវុឌ្ឍិនៃការជ្រើសរើស ការរៀបចំ ការផ្តល់តួនាទី និងការលើកទឹកចិត្តគ្រូបង្រៀន រំលេចពីគោលជំហររបស់រដ្ឋាភិបាលលើស្ថានភាពវិជ្ជាជីវៈគ្រូបង្រៀន និងលទ្ធផលរំពឹងទុកនៃស្តង់ដារប្រតិបត្តិរបស់គ្រូបង្រៀន។

## ៣ .ធនធានគាំទ្រផ្សេងៗ

ក្រៅពីថវិកាប្រចាំឆ្នាំសម្រាប់វិស័យអប់រំ ធនធានដែលគាំទ្រដល់ផ្នែកថែទាំ និងអប់រំកុមារតូច មានប្រភពទូលំទូលាយមកពីវិស័យរដ្ឋ និងឯកជន។ គោលការណ៍ណែនាំរបស់រដ្ឋាភិបាលលើការប្រើប្រាស់ដី ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ មានឥទ្ធិពលដោយផ្ទាល់លើធនធានដែលមានស្រាប់សម្រាប់មជ្ឈមណ្ឌលថែទាំ និងអប់រំកុមារតូច។ វិស័យឯកជន ជាចលករធនធានដ៏មានសក្តានុពល ដូចជាការផ្តល់ការគាំទ្ររបស់ក្រុមហ៊ុនលើគម្រោងជួយសង្គម ឬការគាំទ្រក្នុងទម្រង់ផ្សេងទៀតមកពីគម្រោងជួយសហគមន៍ធំៗ។

ក្របខ័ណ្ឌនេះ ជំរុញឱ្យសមាសភាគទាំងបីក្នុងប្រព័ន្ធម៉ាក្រូមានអន្តរកម្មជាមួយគ្នា ដើម្បីធ្វើឱ្យលទ្ធផលនៃការថែទាំ និងអប់រំកុមារតូចមានភាពល្អប្រសើរឡើង។ ឧទាហរណ៍ វត្តមាននៃស្តង់ដារថែទាំ និងអប់រំកុមារតូចប្រកបគុណភាពក្នុងប្រទេសមួយ តម្រូវឱ្យគ្រូបង្រៀនមានចំនួនម៉ោងជាក់លាក់លើការបណ្តុះបណ្តាល ឬចុះកម្មសិក្សា ដែលអាចជួយពង្រឹងវិធីសាស្ត្របង្រៀនរបស់ពួកគេបន្ថែម។ ស្ថានសេដ្ឋកិច្ចសង្គមដែលមានស្រាប់ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធម៉ាក្រូ មានឥទ្ធិពលទៅលើសមាសភាគផ្សេងៗគ្នាដូចជាការបង្កើតច្បាប់ និងបទដ្ឋានជាតិ។ ការជួយទំនុកបម្រុងធនធានផ្សេងៗ តម្លៃ និងបទដ្ឋានវប្បធម៌ អាចមានឥទ្ធិពលលើខ្លឹមសារ និងគរុកោសល្យនៃកម្មវិធីសិក្សាថែទាំ និងអប់រំកុមារតូច។ សមាសភាគនៃទិដ្ឋភាពថែទាំ និងអប់រំកុមារតូចទាំងនេះ មានឥទ្ធិពលលើប្រព័ន្ធមីក្រូ ពោលគឺសាលារៀន និងបរិស្ថានសិក្សា។

ដោយសារតួនាទីរបស់អ្នកអប់រំកុមារត្រូវបានគូសបញ្ជាក់នៅក្នុងការស្រាវជ្រាវផ្សេងៗ ក្របខ័ណ្ឌនេះចាត់ទុកគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចជាចំណុចស្នូល។ ដោយស្ថិតនៅក្នុងបរិស្ថានសិក្សាផ្សេងៗគ្នាដូចជា មជ្ឈមណ្ឌលថែទាំ មត្តេយ្យសិក្សា មជ្ឈមណ្ឌលទារកដ្ឋាន និងមជ្ឈមណ្ឌលថែទាំនិងអប់រំកុមារតូចបែបសាសនា គ្រូបង្រៀនត្រូវបានគេចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងកុមារ។ ទំនាក់ទំនងរវាងកុមារ និងគ្រូ ត្រូវបានគេសម្គាល់ថាជាដំណើរការដ៏ជិតស្និតដែលមានសារៈសំខាន់ចំពោះការរីកចម្រើនរបស់កុមារ។ ដូច្នេះក្របខ័ណ្ឌនេះ បង្ហាញថា បទពិសោធន៍ការងារ គុណវុឌ្ឍិ និងចរិតលក្ខណៈរបស់គ្រូ គឺជាសមាសភាគដ៏មានសារៈសំខាន់ ដែលរួមចំណែកលើលទ្ធផលនៃការរីកចម្រើនគ្រប់ផ្នែករបស់កុមារ។

លើសពីនេះទៀត ក្របខ័ណ្ឌនេះទទួលស្គាល់ថា គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចជាបុគ្គលិក ដែលតម្រូវឱ្យមានការបណ្តុះបណ្តាលឯកទេស និងបន្តការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈការងាររបស់ពួកគេ។ គ្រូបង្រៀន គឺអ្នកសិក្សាពេញមួយជីវិត ដែលត្រូវការអភិវឌ្ឍចំណេះដឹង និងជំនាញជាប្រចាំ។ ពួកគេត្រូវការឱកាសដើម្បីឆ្លុះបញ្ចាំងលើការពង្រឹងការអនុវត្តវិជ្ជាជីវៈបង្រៀនរបស់ពួកគេផ្ទាល់ខ្លួន និងជាសមូហភាព។

អំឡុងពេលសិក្ខាសាលាផ្ទៀងផ្ទាត់សម្រាប់ក្របខ័ណ្ឌប្រទេសតំបន់អាស៊ីអាគ្នេយ៍ អ្នកចូលរួម បានបង្ហាញក្តីសង្ឃឹមរបស់ពួកគេចំពោះគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលមានគុណវុឌ្ឍិអប់រំគ្រប់គ្រាន់ដូចជា សញ្ញាបត្រជំនាញអប់រំកុមារតូច។ ចំពោះប្រទេសដែលមានបញ្ហាប្រឈមផ្នែកថវិកា និងឆ្លើយតបតម្រូវការរបស់គ្រូដែលមានគុណវុឌ្ឍិការកំណត់ឱ្យគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ត្រូវទទួលបានសញ្ញាបត្រមុនពេលពួកគេអនុញ្ញាតឱ្យបង្រៀនប្រហែលជាត្រូវការកិច្ចខិតខំប្រឹងប្រែងរួមគ្នាបន្ថែមទៀតពីភ្នាក់ងារ និងក្រសួងពាក់ព័ន្ធផ្សេងៗ ក្នុងការអប់រំ និងថែទាំកុមារតូច។

អំឡុងពេលសិក្ខាសាលានេះផងដែរ អ្នកចូលរួមបានកំណត់អំពីលក្ខណៈ និងលក្ខខណ្ឌវិនិច្ឆ័យរួមរបស់គ្រូផ្នែកថែទាំ និងអប់រំកុមារតូច លើសពីចំណេះដឹង និងជំនាញ ដែលជាការរំពឹងទុករបស់គ្រូបង្រៀនដូចខាងក្រោម។ លក្ខណៈ និងលក្ខខណ្ឌវិនិច្ឆ័យទាំងនេះ បង្ហាញអំពីតម្លៃ ជំនឿនិងជំនាញក្នុងការសម្រេចចិត្ត និងអនុវត្តសកម្មភាពការងារប្រចាំថ្ងៃរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។

- ចិត្តល្អ អត់ធ្មត់ និងរួសរាយរាក់ទាក់
- មានក្តីស្រលាញ់ចំពោះកុមារ
- ស្គាល់បរិបទ និងលក្ខខណ្ឌរបស់កុមារ
- ឆ្លុះបញ្ចាំងដើម្បីរកវិធីពង្រឹងការអនុវត្តក្នុងការដោះស្រាយជាមួយកុមារ
- មានទំនាក់ទំនងល្អជាមួយអ្នកដទៃ
- មានសុខភាពល្អ និងអនុវត្តការថែទាំខ្លួនឯង
- មានភាពបត់បែន និងច្នៃប្រឌិត
- ជាគំរូល្អសម្រាប់កុមារ
- មានវិន័យវិជ្ជមាន
- មានការចូលរួម និងជំរុញការអភិវឌ្ឍនិងការរៀនសូត្ររបស់កុមារ
- មានឆន្ទៈអភិវឌ្ឍខ្លួនឯង

ខណៈពេលដែលលក្ខខណ្ឌវិនិច្ឆ័យមិនត្រូវបានកំណត់យ៉ាងពិសេសក្នុងក្របខ័ណ្ឌនេះ វាមានសារៈសំខាន់ដែលត្រូវដឹងថា លក្ខខណ្ឌវិនិច្ឆ័យមូលដ្ឋានខាងលើនេះ មានការជាប់ទាក់ទងយ៉ាងសំខាន់សម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។

## ការយល់ដឹងអំពីសមាសធាតុនៃក្របខ័ណ្ឌ

ក្នុងការប្រើប្រាស់ក្របខ័ណ្ឌគ្រូផ្នែកថែទាំ និងអប់រំកុមារតូចនេះ វាជាការសំខាន់ដែលត្រូវដឹងថាក្របខ័ណ្ឌនេះមានលំហូរតាមលំដាប់លំដោយស្របតាមលក្ខណៈសមហេតុផល និងរីកចម្រើន។ ចំណុចនេះ នឹងពិភាក្សាលើសមត្ថភាពក្នុងផ្នែកទាំងបួនរួមមាន៖ (១) ចំណេះដឹងជំនាញ ការប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ (២) បរិយាកាសរៀនសូត្រ (៣) ការចូលរួមនិងកិច្ចសហការ (៤) និងការអភិវឌ្ឍវិជ្ជាជីវៈ។ សមត្ថភាពស្នូលទាំងប្រាំពីរ នឹងត្រូវបានយកមកពិភាក្សានៅចំណុចបន្ទាប់ក្នុងផ្នែកសមត្ថភាពឆ្លើយឆ្លង (corresponding competency) និងសមត្ថភាពគាំទ្រឬជំរុញ (enabling competencies) ដែលនឹងពន្យល់បន្ថែមអំពីការគាំទ្រនៃសមត្ថភាពទាំងនេះ លើលទ្ធផលសម្រេចនៃសមត្ថភាពស្នូលទាំងប្រាំពីរ។

## សមត្ថភាពចំណេះដឹងជំនាញ ការប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ

បណ្តុំសមត្ថភាពដំបូង ដែលជាសមត្ថភាពចំណេះដឹងជំនាញ ការប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ មានសារៈសំខាន់បំផុតសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ ផ្នែកនេះគ្របដណ្តប់លើសមត្ថភាពស្នូលចំនួនពីរគឺ ការយល់ដឹងអំពីការរៀនសូត្រនិងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ និងការសម្របសម្រួលការរៀនសូត្រនិងការអភិវឌ្ឍរបស់កុមារ។ សមត្ថភាពស្នូលទាំងនេះ គាំទ្រដោយបណ្តុំសមត្ថភាពគាំទ្រ ឬជំរុញទាំង២១ ដែលអាចជួយឱ្យគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចបង្ហាញសមត្ថភាពរបស់ពួកគេលើផ្នែកចំណេះជំនាញ ការប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ។

ឧទាហរណ៍ក្នុងសមត្ថភាពស្នូលដំបូង គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងចំណោមគ្រូបង្រៀនដទៃទៀត អាចយល់ដឹងអំពីមូលដ្ឋានគ្រឹះនៃការសិក្សា និងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ។ លើសពីនេះទៀត ក្របខ័ណ្ឌប្រទេសតំបន់អាស៊ីអាគ្នេយ៍ ផ្តោតសំខាន់បំផុតលើគោលការណ៍នានាផ្អែកលើសិទ្ធិជាមូលដ្ឋានដែលបានកំណត់ដោយស្ថាប័នអន្តរជាតិក្នុងការទទួលស្គាល់ការអប់រំជាសិទ្ធិមូលដ្ឋានគ្រឹះក្នុងវដ្តនៃជីវិតរបស់មនុស្ស (សូមមើលជាឧទាហរណ៍ UNICEF and UNESCO, 2007)។ ដូច្នេះ វាជាសមត្ថភាពគាំទ្រ ឬជំរុញ ដែលសំខាន់បំផុតសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។

គ្រូបង្រៀនអាចយល់ដឹងអំពីដំណាក់កាលផ្សេងៗ និងបរិបទនៃការអភិវឌ្ឍរបស់កុមារ។ ដូច្នេះហើយ ក្រៅពីមានចំណេះដឹងផ្នែកទ្រឹស្តីនៃការអភិវឌ្ឍរបស់កុមារគ្រប់ផ្នែក គ្រូបង្រៀនត្រូវបានរំពឹងថាយល់ដឹងអំពីច្បាប់ គោលនយោបាយ បទដ្ឋាននានាដែលពាក់ព័ន្ធ យ៉ាងហោចណាស់ក្នុងបរិបទប្រទេសរបស់ខ្លួន។ ចំណេះដឹងអំពីដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ ជួយគ្រូបង្រៀនអាចកំណត់បាននូវអត្តសញ្ញាណកុមារដែលងាយរងគ្រោះ និងមានតម្រូវការពិសេស។

ការយល់ដឹងអំពីការរៀនសូត្រនិងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ អាចជួយឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពសម្រាប់ការរៀនសូត្រ និងការអភិវឌ្ឍកុមារ។ ឧទាហរណ៍ ដោយមានចំណេះដឹងគ្រប់គ្រាន់លើការរៀនសូត្រនិងការអភិវឌ្ឍកុមារ និងដោយមានគោលការណ៍ណែនាំ ឬកម្មវិធីសិក្សាស្តីពីការថែទាំនិងអប់រំកុមារតូច គ្រូបង្រៀនអាចរៀបចំ និងអនុវត្តកម្មវិធីថែទាំ និងអប់រំកុមារតូចបានសមស្រប។ ម្យ៉ាងវិញទៀត គ្រូបង្រៀនអាចយល់ដឹងអំពីសារៈសំខាន់នៃសកម្មភាពលេង ថាជាផ្នែកមួយនៃការរៀនសូត្រ និងផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍនិងការរៀនសូត្រដោយផ្អែកលើសកម្មភាពលេងជាមូលដ្ឋាន។

ការយល់ដឹងអំពីបរិបទនៃការរៀនសូត្រនិងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ ជួយឱ្យគ្រូបង្រៀនមានសមត្ថភាពអាចប្រើប្រាស់ឧបករណ៍ និងវិធីសាស្ត្រដែលមានស្រាប់និងសមស្រប ដើម្បីផ្តល់ភាពងាយស្រួលដល់ការរៀនសូត្រ និងការអភិវឌ្ឍកុមារ។ ដោយមានការផ្តោតសំខាន់លើការអប់រំពហុភាសាផ្អែកលើភាសាកំណើត (MTB-MLE) (សូមមើលជាឧទាហរណ៍ UNESCO, 2013) ការទំនាក់ទំនងដោយប្រើប្រាស់ភាសាកំណើត និងភាសាដំបូងរបស់កុមារ ជាសមត្ថភាពមួយដែលរំពឹងទទួលបានពីគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចសម្រាប់កុមារដែលប្រើប្រាស់ភាសាជនជាតិភាគតិច។ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) ក្នុងការពង្រឹងការរៀនសូត្រផ្ទាល់ខ្លួនរបស់គ្រូ និងក្នុងថ្នាក់រៀននៅពេលសមស្របណាមួយ ជាសមត្ថភាពជាក់លាក់ដែលគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចរំពឹងថាអាចអនុវត្តបាន និងត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌសមត្ថភាពនេះ។ ហើយវាក៏ស្របជាមួយនឹងសមត្ថភាពរបស់គ្រូ ដែលត្រូវបានកំណត់ក្នុងគោលការណ៍ណែនាំនៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។

នៅក្នុងគោលការណ៍ណែនាំនៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ សមត្ថភាពពិនិត្យតាមដាន និងការវាយតម្លៃ (assessment and evaluation competencies) អាចសំដៅលើ "ចំណេះដឹងអំពីឧបករណ៍នានាក្នុងការវាយតម្លៃការរៀនសូត្រនិងការអភិវឌ្ឍរបស់កុមារ យន្តការនៃការផ្តល់ព័ត៌មានត្រឡប់ និងចំណេះដឹងអំពីប្រព័ន្ធប្រមូលទិន្នន័យ" "ការវាយតម្លៃតាមដំណាក់កាលដែលគាំទ្រតម្រូវការរៀនសូត្រផ្ទាល់ខ្លួនរបស់កុមារ" និង "សមត្ថភាពក្នុងការកំណត់ និងឆ្លើយតបសមស្រមចំពោះតម្រូវការពិសេសរបស់កុមារដូចជា កុមារដែលលូតលាស់យឺត ឬកុមារមានពិការភាព" (Ibid: p.16)។ សមាសភាគទាំងនេះ ត្រូវបានដាក់បញ្ចូលក្នុងក្របខ័ណ្ឌសមត្ថភាពនេះ ទោះបីជាត្រូវបានដាក់ឱ្យស្ថិតនៅក្នុងក្រុមសមត្ថភាពទូទៅស្តីពីការជួយជំរុញការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារក៏ដោយ។

នៅក្នុងបរិបទប្រទេសតំបន់អាស៊ីអាគ្នេយ៍ វាមានសារៈសំខាន់ខ្លាំងណាស់ដែលត្រូវកត់សម្គាល់ថា សមត្ថភាពពាក់ព័ន្ធនឹងការពិនិត្យតាមដានត្រូវបានដាក់បញ្ចូលនៅក្នុងផ្នែកសមត្ថភាពចំណេះដឹងជំនាញ ការប្រតិបត្តិគរុកោសល្យ និងការវាយតម្លៃ ដែលជំរុញឱ្យមានការប្រកាន់ភ្ជាប់នូវភាពចាំបាច់ក្នុងការវាយតម្លៃ ដើម្បីពិនិត្យការរីកចម្រើនក្នុងការរៀនសូត្រនិងការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ។ ទិដ្ឋភាពរួមនៃការប្រកាន់យកសមត្ថភាពទាក់ទងនឹងការពិនិត្យតាមដានក្នុងក្របខ័ណ្ឌគ្រូផ្នែកថែទាំ និងអប់រំកុមារតូចនៃប្រទេសតំបន់អាស៊ីអាគ្នេយ៍ មានភាពខុសគ្នាពីក្របខ័ណ្ឌផ្សេងទៀតដូចជា សមត្ថភាពដែលកំណត់ក្នុងគោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រង និងអភិវឌ្ឍគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនៃប្រទេសជាសមាជិកស៊ីមេអូ (UNESCO and SEAMEO 2016) និងក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចសម្រាប់ប្រទេសកំពុងអភិវឌ្ឍដែលជាប្រជុំកោះតូចៗ (SIDS)។ ដូច្នេះ នៅពេលយកក្របខ័ណ្ឌនេះទៅអនុវត្តក្នុងបរិបទរបស់ខ្លួន អ្នកប្រតិបត្តិថែទាំ និងអប់រំកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍ គួរពិចារណាលើភាពសមស្របក្នុងការកំណត់អំពីការពិនិត្យតាមដានជាសមត្ថភាពដោយឡែកពីគេសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។

ប្រអប់ទី១. សមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងផ្នែកចំណេះដឹងជំនាញ ការប្រតិបត្តិឥរុកោសល្យ និងការវាយតម្លៃ។

| សមត្ថភាពទូទៅ និងស្នូល | សមត្ថភាពគាំទ្រ និងជំរុញ |
|---|---|
| ១. **យល់ដឹងអំពីការរៀនសូត្រ និងការអភិវឌ្ឍគ្រប់គ្រប់ផ្នែក៖** ទាំងនេះគឺជាសមត្ថភាពពាក់ព័ន្ធនឹងការយល់ដឹងលើផ្នែកទ្រឹស្តីនិងការអភិវឌ្ឍ និងការយល់ដឹងអំពីការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ សម្រាប់គ្រូបង្រៀនថែទាំ និងអប់រំកុមារតូច។ | ១- បង្ហាញការយល់ដឹងអំពីសិទ្ធិកុមារ។<br>២- បង្ហាញការគោរពដល់សិស្ស និងផ្តោតការយកចិត្តទុកដាក់ចំពោះសិស្សលើសកម្មភាពរៀន និងបង្រៀន។<br>៣- ផ្សារភ្ជាប់ខ្លួនឯងនូវចំណេះដឹងលើការរៀន និងការអភិវឌ្ឍកុមារគ្រប់ផ្នែក រួមបញ្ចូលទ្រឹស្តីនៃការអភិវឌ្ឍកុមារតូច។<br>៤- ផ្សារភ្ជាប់ខ្លួនឯងនូវចំណេះដឹងពាក់ព័ន្ធនឹងច្បាប់ គោលនយោបាយ និងបទដ្ឋាននៃការថែទាំ និងអប់រំកុមារតូច។<br>៥- ពន្យល់អំពីចំណេះដឹងពាក់ព័ន្ធស្តីពីការរៀនសូត្រ និងការអភិវឌ្ឍកុមារទៅកាន់សហការី ឪពុកម្តាយ និងភាគីថែទាំ និងអប់រំកុមារតូចពាក់ព័ន្ធផ្សេងទៀត។<br>៦- ទទួលស្គាល់ថា កុមារដែលអភិវឌ្ឍនៅដំណាក់កាលផ្សេងគ្នាមានតម្រូវការ ចំណង់ចំណូលចិត្ត និងសក្តានុពលខុសៗគ្នា។<br>៧- អាចអង្កេត និងបរិយាយនូវលក្ខណៈអភិវឌ្ឍរបស់កុមារ ( ឧទាហរណ៍៖ ការគិតភាសា រូបរាងកាយ អារម្មណ៍ និងស្មារតី)។<br>៨- កំណត់អត្តសញ្ញាណកុមារដែលងាយទទួលរងគ្រោះ និងមានតម្រូវការជាពិសេស។<br>៩- យល់ដឹងថាកុមារមានការអភិវឌ្ឍក្នុងបរិបទគ្រួសារ និងសហគមន៍របស់ខ្លួន។ |

| សមត្ថភាពទូទៅ និងស្នូល | សមត្ថភាពគាំទ្រ និងជំរុញ |
| --- | --- |
| **២. ជួយសម្រួលដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ៖** ទាំងនេះជាសមត្ថភាពពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដើម្បីជួយសម្រួលដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ ដែលរួមបញ្ចូលការប្រើប្រាស់ឧបករណ៍វាយតម្លៃ វិធីសាស្ត្រ និងលទ្ធផលដើម្បីជួយគាំទ្រការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ។ | ១- រៀបចំ និងអភិវឌ្ឍភាសាវិទ្យា ការប្រតិបត្តិនៃការបញ្ច្រាបយេនឌ័រ និងវប្បធម៌ក្នុងការគ្រប់គ្រងថ្នាក់រៀនដោយផ្អែកលើគោលការណ៍ឯកភាពស្តីពីកម្មវិធីសិក្សា ឬក្របខ័ណ្ឌថ្នាក់ជាតិ។<br>២- ប្រើប្រាស់ចំណេះដឹងនៃការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារដើម្បីធ្វើផែនការ រៀបចំ និងអនុវត្តកម្មវិធីថែទាំ និងអប់រំកុមារតូច។<br>៣- ជំរុញ និងផ្តល់ឱកាសសម្រាប់សកម្មភាពលេង ដើម្បីគាំទ្រការរៀនសូត្រ និងការអភិវឌ្ឍកុមារ។<br>៤- ជំរុញ និងអនុវត្តសកម្មភាពគ្រប់គ្រងថ្នាក់រៀនដែលមានភាពសមស្របតាមការអភិវឌ្ឍរបស់កុមារ វិធីសាស្ត្រ និងការប្រតិបត្តិសម្រាប់សិស្សដែលមានជីវប្រវត្តិផ្សេងគ្នា។<br>៥- ប្រើប្រាស់សកម្មភាពផ្អែកលើសកម្មភាពលេងជាមូលដ្ឋាន និងវិធីសាស្ត្ររៀននិងបង្រៀនដែលជំរុញឱ្យមានការគិតស៊ីជម្រៅ និងច្នៃប្រឌិត ការធ្វើសេចក្តីសម្រេចចិត្ត ការដោះស្រាយបញ្ហា និងជួយឱ្យកុមារក្លាយជាអ្នកសិក្សាសកម្ម។<br>៦- ប្រើប្រាស់ឧបករណ៍ វិធីសាស្ត្រ និងបច្ចេកវិទ្យាសមស្រប រួមបញ្ចូលនូវបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដើម្បីសម្រួលដល់ការអភិវឌ្ឍ និងដោះស្រាយនូវតម្រូវការអភិវឌ្ឍរបស់កុមារ។<br>៧- រៀបចំ ដាក់បញ្ចូល និងបត់បែនការប្រើប្រាស់ចំណេះដឹងផ្នែកវប្បធម៌ និងសម្ភារសិក្សាដែលផលិតក្នុងស្រុក/ក្រៅស្រុក ឱ្យស្របតាមខ្លឹមសារមេរៀន និងសកម្មភាពផ្សេងៗ ដើម្បីពង្រឹងបទពិសោធន៍រៀនសូត្រក្នុង និងក្រៅសាលា។<br>៨- ទំនាក់ទំនងដោយប្រើប្រាស់ភាសាកំណើត ឬភាសាទី១របស់សិស្សក្នុងការរៀន និងបង្រៀនតាមស្ថានភាពសមស្រប និងអាចធ្វើទៅបាន។<br>៩- តាមដាន រក្សាទុក និងឆ្លុះបញ្ចាំងលើការអភិវឌ្ឍ និងការរីកចម្រើនរបស់កុមារ ដោយស្របតាមស្តង់ដារអភិវឌ្ឍការសិក្សាដំបូង ដែលបានអនុម័តរួច។ |

| | |
|---|---|
| | ១០- ប្រើប្រាស់លទ្ធផលនៃការពិនិត្យតាមដាន សម្រាប់ជាព័ត៌មានក្នុងការរៀបចំសកម្មភាពនាពេលអនាគត។<br><br>១១- ប្រើប្រាស់លទ្ធផលនៃការពិនិត្យតាមដាន ដើម្បីធ្វើជាដើមទុនសម្រាប់កំណត់សអត្តសញ្ញាណកុមារងាយរងគ្រោះ និងកុមារលូតលាស់យឺត ឬកុមារដែលមានតម្រូវការពិសេសសម្រាប់ធ្វើការវិនិច្ឆ័យ គាំទ្រ និងធ្វើអន្តរាគមន៍បន្ត។<br><br>១២- ប្រើលទ្ធផលនៃការពិនិត្យតាមដាន ដើម្បីវាយតម្លៃ និងកំណត់ការអន្តរាគមន៍សម្រាប់ការត្រៀមខ្លួន ការផ្លាស់ប្តូររបស់កុមារសម្រាប់ការអប់រំនៅបឋមសិក្សា។ |

## បរិយាកាសនៃការរៀនសូត្រ

នៅតំបន់អាស៊ីអាគ្នេយ៍ ការបង្កើតបរិយាកាសនៃការរៀនសូត្រឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍របស់កុមារ ត្រូវបានគេមើលឃើញថាមានសារៈសំខាន់ណាស់។ មិនថាបរិយាកាសនៃការរៀនសូត្រនេះស្ថិតនៅកន្លែងដែលគ្រប់គ្រងដោយសហគមន៍ កន្លែងសិក្សានៅទីជំនឿសាសនា មណ្ឌលសេវាថែទាំកុមារដែលផ្តល់ថវិកាដោយរដ្ឋ ឬសាលាមត្តេយ្យឯកជននោះឡើយ វាសំខាន់ណាស់ដែលគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច (ECCE) ធានាថាទាំងកន្លែងសិក្សានៅក្នុងផ្ទះនិងក្រៅផ្ទះ ត្រូវមានសុវត្ថិភាព អនាម័យ និងអំណោយផលសម្រាប់ការរៀនសូត្រ និងការអភិវឌ្ឍរបស់កុមារ។ ក្រៅពីរចនាសម្ព័ន្ធរូបវន្ត គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចដែលមានសមត្ថភាព ក៏អាចធានាផងដែរថាសុខភាព សុវត្ថិភាព ការការពារ និងសុខុមាលភាពទូទៅរបស់កុមារត្រូវបានទទួលការការពារ និងលើកម្ពស់។

ដូច្នេះ ក្របខ័ណ្ឌសមត្ថភាពនេះ ទទួលស្គាល់នូវសមត្ថភាពស្នូលចំនួនពីរដែលស្ថិតក្នុងផ្នែកបរិយាកាសនៃការរៀនសូត្រគឺ ការបង្កើតបរិយាកាសដែលមានការថែទាំចិញ្ចឹមបីបាច់កុមារ មានសុវត្ថិភាពនិងប្រកបដោយបរិយាបន្ន និងការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ សុវត្ថិភាព និងការការពារកុមារ។ សមត្ថភាពទាំងនេះ ត្រូវបានគាំទ្រដោយសំណុំនៃអនុសមត្ថភាពចំនួនម្ភៃប្រាំ ដែលអាចឱ្យគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច បង្ហាញនូវសមត្ថភាពក្នុងផ្នែកបរិយាកាសសិក្សារបស់កុមារ។

ក្នុងចំណោមសមត្ថភាពដែលអាចរកបានមុនគេរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច គឺការផ្តល់និងការបង្កើតបរិយាកាសរៀនសូត្រ និងការអភិវឌ្ឍប្រកបដោយភាពអំណោយផល ដែលគិតគូរលើផ្នែកសង្គមនិងអារម្មណ៍ និងតម្រូវការលូតលាស់ផ្នែករាងកាយរបស់កុមារ ហើយដែលអនុញ្ញាតឱ្យកុមារមានអារម្មណ៍ថា ទទួលបានការចិញ្ចឹមបីបាច់សុវត្ថិភាព និងការការពារ។ លើសពីនេះទៀត វាស្របទៅនឹងរបៀបវារៈអភិវឌ្ឍន៍ទាំងឡាយ ដែលធានានូវបរិយាបន្នសម្រាប់អ្នកសិក្សាទាំងអស់ គ្រូអាចផ្តល់នូវបរិកាសរៀនសូត្រ និងអាចបង្ហាញពីការប្រតិបត្តិប្រកបដោយបរិយាបន្ននានា ដែលជួយជំរុញដល់ការដាក់បញ្ចូលកុមារទាំងអស់ ជាពិសេសកុមារដែលមានតម្រូវការពិសេសក្នុងសកម្មភាពរៀនសូត្រ និងអភិវឌ្ឍន៍។

ជាថ្មីម្តងទៀត ស្របតាមគោលការណ៍ណែនាំអាស៊ីអាគ្នេយ៍ ស្តីពីសមត្ថភាពខាងភាសា និងវប្បធម៌ ព្រមទាំងសមត្ថភាពខាងបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ និងសមត្ថភាពក្នុងការដោះស្រាយភាពអាសន្ន ត្រូវបានគេដាក់បញ្ចូលក្នុងចំណោមសមត្ថភាពដែលអាចធ្វើទៅបានសម្រាប់ដែនបរិយាកាសនៃការរៀនសូត្រ។

ប្រអប់ ២. សមត្ថភាពរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច *ECCE* ក្នុងផ្នែកបរិយាកាសនៃការសិក្សា។

| សមត្ថភាពស្នូល/ទូទៅ | សមត្ថភាពគាំទ្រ |
|---|---|
| ៣. **បង្កើតបរិយាកាសដែលមានសុវត្ថិភាព ប្រកបដោយបរិយាបន្ន និងការលូតលាស់របស់កុមារ៖** ចំណុចនេះទាក់ទងនឹងសមត្ថភាពរបស់គ្រូបង្រៀនក្នុងការបង្កើតបរិយាកាសអំណោយផលសម្រាប់កុមារ | ១- ផ្តល់នូវបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព និងអំណោយផលដែលអាចឱ្យកុមារមានអារម្មណ៍ថា មានសុវត្ថិភាព ត្រូវបានការពារ និងទទួលការចិញ្ចឹមបីបាច់ ។<br>២- បង្កើនបរិយាកាសដែលប្រកបដោយសុវត្ថិភាព និងអំណោយផលសម្រាប់កុមារដែលគិតគូរអំពីតម្រូវការខាងរាងកាយ អារម្មណ៍ និងតម្រូវការខាងសង្គម របស់កុមារទាំងអស់។<br>៣- ផ្តល់នូវបរិកាសដែលខ្វល់ខ្វាយអំពីវប្បធម៌ ភាសា និងយេនឌ័រ ដែលលើកទឹកចិត្តដល់ការដាក់បញ្ចូលកុមារទាំងអស់ រួមទាំងកុមារមានតម្រូវការពិសេស។<br>៤- ផ្តល់បរិយាកាសមួយដែលគាំទ្រដល់កម្មវិធីដែលមានភាពសព្វគ្រប់ រួមបញ្ចូល សុខភាព អាហារូបត្ថម្ភ ការរៀនសូត្រកម្រិតមត្តេយ្យ និងការការពារកុមារ។<br>៥- រៀបចំបរិយាកាសដែលជំរុញដល់ការគិតបែបត្រិះពិចារណា ការច្នៃប្រឌិត ការទំនាក់ទំនង កិច្ចសហប្រតិបត្តិការ ការចង់ដឹងចង់ឃើញ ការយល់ចិត្ត ការរុករក ការដោះស្រាយបញ្ហា និងការសម្រេចចិត្ត។<br>៦- ធានាថារាល់ធនធានសម្រាប់ថ្នាក់រៀនបច្ចេកវិទ្យានិងសម្ភារៈសិក្សាគ្រប់គ្រាន់ មានសុវត្ថិភាព មានអនាម័យ និងសមស្របសម្រាប់ការរៀន។<br>៧- ផ្តល់ជូននូវសម្ភារៈសិក្សាដែលលើកទឹកចិត្តកុមារឱ្យចេះរុករក និងបង្កើតថ្មី។<br>៨- បង្កើតទម្លាប់នៃការរៀនសូត្រដែលមានភាពសមស្របតាមការអភិវឌ្ឍ ដើម្បីជំរុញឱ្យមានការលើកកម្ពស់សុវត្ថិភាព និងអភិវឌ្ឍទម្លាប់ល្អសម្រាប់កុមារ។<br>៩- ជំរុញការធ្វើអន្តរកម្មជាវិជ្ជមាន រួមមានទំនាក់ទំនងរវាងគ្រូនិងមនុស្សពេញវ័យ រវាងគ្រូនិងកុមារ និងរវាងកុមារនិងមនុស្សពេញវ័យ។<br>១០- ធ្វើអន្តរកម្មជាមួយកុមារគ្រប់រូបដោយក្តីស្រឡាញ់ និងយកចិត្តទុកដាក់។<br>១១- ស្តាប់ដោយយកចិត្តទុកដាក់ និងឆ្លើយតបទៅនឹងតម្រូវការកុមារ។<br>១២- បង្ហាញគំរូវិជ្ជមានជាប់លាប់ ដើម្បីចង្អុលបង្ហាញអាកប្បកិរិយារំពឹងទុករបស់កុមារ។<br>១៣- ខិតខំប្រកាន់យកការអនុវត្តប្រកបដោយបរិយាបន្នសម្រាប់កុមារគ្រប់មជ្ឈដ្ឋាន គ្រប់លក្ខណៈ និងគ្រប់កម្រិតសមត្ថភាព។<br>១៤- ផ្តល់នូវយុទ្ធសាស្ត្រតាមលំដាប់លំដោយ ដើម្បីគាំទ្រការកំណត់ វិន័យជាវិជ្ជមាន និងលើកទឹកចិត្តដល់អាកប្បកិរិយាវិជ្ជមានរបស់កុមារ។ |

| សមត្ថភាពស្នូល/ទូទៅ | សមត្ថភាពគាំទ្រ |
|---|---|
| **៤.លើកកម្ពស់សុខភាព អាហារូបត្ថម្ភ សុវត្ថិភាព និងការការពារ៖** សមត្ថភាពពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនិងការអនុវត្តនានា ដើម្បីធានាថាសុខភាព អាហារូបត្ថម្ភ សុវត្ថិភាព និងតម្រូវការការពាររបស់កុមារត្រូវបានដោះស្រាយ។ | ១- កំណត់ និងភ្ជាប់កុមារជាមួយសេវាកម្មសុខភាព សុវត្ថិភាព អាហារូបត្ថម្ភ និងការការពារដែលមាននៅក្នុងសហគមន៍។<br>២- អនុវត្តគោលនយោបាយ បទប្បញ្ញត្តិ និងការប្រតិបត្តិសមស្របតាមវប្បធម៌ដែលធានា ដល់សុខភាព អាហារូបត្ថម្ភ សុវត្ថិភាព និងការការពារកុមារ។<br>៣- គាំទ្រដល់ការអភិវឌ្ឍជំនាញជួយខ្លួនឯងរបស់កុមារ (ឧទាហរណ៍ការបរិភោគអាហារ ការស្លៀកពាក់ ការធ្វើអនាម័យ និងការប្រើប្រាស់បង្គន់ដោយខ្លួនឯង) ដើម្បីលើកទឹកចិត្តឱ្យកុមារមានទម្លាប់ល្អ និងឯករាជ្យ។<br>៤- ត្រួតពិនិត្យ និងចងក្រងឯកសារស្តីពីតម្រូវការសុខភាព អាហារូបត្ថម្ភ សុវត្ថិភាព និងការការពារជាបន្ទាន់របស់កុមារ។<br>៥- រៀបចំកុមារឱ្យចេះការពារខ្លួនពីការគំរាមកំហែង និងគ្រោះថ្នាក់ដែលអាចកើតមានចំពោះរាងកាយ និងខួរក្បាលពួកគេ (ឧទាហរណ៍ការបង្រៀនកុមារអំពីសុវត្ថិភាពចរាចរណ៍ និងការគំរាមកំហែងពីមនុស្សដែលមិនស្គាល់ជាដើម)។<br>៦- ទទួលស្គាល់កត្តាហានិភ័យ ឬស្ថានភាពមិនល្អនៅក្នុងគ្រួសាររបស់កុមារ (ឧទាហរណ៍ការរំលោភបំពាន អំពើហិង្សាក្នុងគ្រួសារ លក្ខខណ្ឌសុខភាពរបស់ឪពុកម្តាយ) ដែលអាចប៉ះពាល់ដល់សុខភាព សុវត្ថិភាព និងការការពារកុមារ។<br>៧- ស្វែងរក រាយការណ៍ និងប្តឹងលើករណីដែលអាចកើតមាននូវការរំលោភបំពាន ឬការបោះបង់កុមារទៅកាន់អាជ្ញាធរនៅជិតបំផុត។<br>៨- គ្រប់គ្រងការសង្គ្រោះបឋម ដែលជាការឆ្លើយតបដំបូងចំពោះការរងរបួសនិងជំងឺ។<br>៩- ត្រៀមលក្ខណៈឆ្លើយតបឱ្យបានរហ័ស និងសមស្របចំពោះភាពអាសន្នដូចជាគ្រោះថ្នាក់ អគ្គីភ័យ ការបំផ្លិចបំផ្លាញ និងគ្រោះមហន្តរាយផ្សេងៗ។<br>១០- បង្រៀនកុមារឆ្លើយតបឱ្យបានល្អសមស្របក្នុងករណីមានអាសន្ន។<br>១១- ត្រៀមលក្ខណៈរៀបចំដើម្បីឆ្លើយតបឱ្យបានគ្រប់គ្រាន់ និងគាំទ្រដល់តម្រូវការសុខភាព អាហារូបត្ថម្ភ សុវត្ថិភាព ការការពារ និងសុខុមាលភាពរបស់កុមាររួមទាំងអ្នកដែលរងគ្រោះដោយសារការរំលោភបំពាន ឬការបោះបង់ចោល។ |

## ការចូលរួមនិងកិច្ចសហការ

បើក្រឡេកទៅមើលក្របខ័ណ្ឌរបស់ Bronfenbrenner ដែលទទួលស្គាល់សារៈសំខាន់នៃអន្តរកម្មរវាងប្រព័ន្ធផ្សេងៗគ្នា និងទំនាក់ទំនងរបស់តួអង្គផ្សេងៗគ្នានៅក្នុងប្រព័ន្ធនីមួយៗ ការចូលរួមនិងការសហការគ្នាត្រូវបានគេមើលឃើញថា ស្ថិតនៅក្នុងផ្នែកសមត្ថភាពនៃក្របខ័ណ្ឌថែទាំ និងអប់រំកុមារតូច (ECCE)។ គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលមានសមត្ថភាពអាចចូលរួមជាមួយតួអង្គពាក់ព័ន្ធក្នុងការអភិវឌ្ឍកុមារដោយហេតុផលផ្សេងៗគ្នា។ ឧទាហរណ៍ពួកគេអាចរក្សាទំនាក់ទំនងជាប្រចាំជាមួយសមាជិកគ្រួសារ អាណាព្យាបាលឬអ្នកថែទាំកុមារស្របច្បាប់ ដើម្បីផ្តល់ព័ត៌មានត្រឡប់លើបញ្ហានានាទាក់ទងនឹងការអភិវឌ្ឍរបស់កុមារក៏ដូចជាពង្រីកបទពិសោធន៍រៀនសូត្រនៅផ្ទះរបស់ពួកគេ។ លើសពីនេះទៅទៀត គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចអាចសហការជាមួយមិត្តរួមការងារ រួមមានគ្រូបង្រៀននៅកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សាផ្សេងទៀត ដើម្បីចែករំលែកចំណេះដឹងពាក់ព័ន្ធការអភិវឌ្ឍរបស់

កុមារ ព្រមទាំងជានានូវលទ្ធផលនៃការសិក្សាជាប់ជាប្រចាំនៅពេលដែលពួកគេផ្លាស់ទៅសាលារៀននៅបឋមសិក្សា។

ក្នុងករណីខ្លះគ្រូក៏ត្រូវបានគេរំពឹងថានឹងពង្រីកតួនាទីរបស់ខ្លួន ជាអ្នកផ្តល់សេវានៃការរៀនសូត្ររបស់កុមារនៅក្នុងថ្នាក់រៀន គ្រូក៏ជាអ្នកតស៊ូមតិដ៏រឹងមាំលើកិច្ចការថែទាំ និងអប់រំកុមារតូច(ECCE) ផងដែរ។ ពេលខ្លះពួកគេអាចប្រមូលធនធានពីអ្នកពាក់ព័ន្ធ ក្នុងផ្នែកថែទាំ និងអប់រំកុមារតូច ផ្សេងៗ។ ស្របពេលជាមួយគ្នានេះដែរ ពួកគេត្រូវមានសមត្ថភាពខ្ពស់បន្ថែមទៀត ដែលមានដូចជាការរៃអង្គាសមូលនិធិ ដើម្បីផ្ទេរទៅឱ្យអ្នកគ្រប់គ្រងទីកន្លែងថែទាំ និងអប់រំកុមារតូច(ECCE) យ៉ាងហោចណាស់គ្រូ គួរតែអាចប្រាប់ពីតម្រូវការទាំងនោះទៅអ្នកត្រួតពិនិត្យ និងអាជ្ញាធរពាក់ព័ន្ធរបស់ខ្លួន។

ប្រអប់ ៣. សមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងផ្នែកការចូលរួម និង ការសហការ។

| សមត្ថភាពស្នូល/ទូទៅ | សមត្ថភាពគាំទ្រ |
|---|---|
| **៥.ធ្វើឱ្យឪពុកម្តាយនិងក្រុមគ្រួសារចូលរួមពាក់ព័ន្ធជាដៃគូរក្នុងកិច្ចថែទាំ និងអប់រំកុមារតូច៖** សមត្ថភាពចូលរួមពាក់ព័ន្ធ នឹងការធ្វើការងារជាមួយក្រុមគ្រួសារ និងអ្នកថែទាំកុមារដោយទាញឱ្យពួកគេក្លាយជាដៃគូនៅក្នុងកិច្ចថែទាំ និងអប់រំកុមារតូច | ១- បង្កើតការប្រាស្រ័យទាក់ទងដោយបើកចំហជាមួយឪពុកម្តាយ និងក្រុមគ្រួសាររបស់កុមារដោយប្រើយុទ្ធសាស្ត្រ និងបច្ចេកវិទ្យាសមស្រប។<br>២- កសាង និងថែរក្សានូវការទុកចិត្តគ្នាទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការជាមួយឪពុកម្តាយ និងក្រុមគ្រួសារកុមារ។<br>៣- ពន្យល់ពីកម្មវិធីថែទាំ និងអប់រំកុមារទៅកាន់ឪពុកម្តាយ ក្រុមគ្រួសារនិងអ្នកថែទាំកុមារ ដោយសហការជាមួយពួកគេដើម្បីពង្រីកនិងពង្រឹងបទពិសោធន៍វិជ្ជមាននៃការរៀននៅផ្ទះ។<br>៤- រៀបចំ និងអនុវត្តផែនការ សកម្មភាព ឬកម្មវិធីសម្រាប់ឪពុកម្តាយ ក្រុមគ្រួសារ និងអ្នកថែទាំ ដើម្បីគាំទ្រដល់ការថែទាំនិងអប់រំកុមារតូច។<br>៥- លើកទឹកចិត្តដល់ការចូលរួមរបស់ឪពុកម្តាយនិងក្រុមគ្រួសារក្នុងសកម្មភាពថ្នាក់រៀន។<br>៦- លើកទឹកចិត្តឱ្យមានការចូលរួមពីគំរូបុរសវិជ្ជមាន (ឧទាហរណ៍ជីតា ឪពុក បងប្អូនប្រុសៗ។ល។) នៅក្នុងថែទាំ និងអប់រំកុមារតូច។<br>៧- ឱ្យឪពុកម្តាយ ឬក្រុមគ្រួសារចូលរួមពាក់ព័ន្ធក្នុងការវាយតម្លៃកុមារ និងផ្តល់នូវមតិកែលម្អ ដើម្បីឱ្យអ្នកពាក់ព័ន្ធទាំងនោះជួយដល់ការអភិវឌ្ឍ និងវឌ្ឍនភាពរបស់កុមារនៅផ្ទះ។<br>៨- ជូនដំណឹង និងលើកទឹកចិត្តដល់ឪពុកម្តាយ ឬក្រុមគ្រួសារឱ្យមានការចូលរួមក្នុងសេវាកម្មសហគមន៍ស្តីពីសុខភាព អាហារូបត្ថម្ភ សុវត្ថិភាព និងការការពារកុមារ។ |

| សមត្ថភាពស្នូល/ទូទៅ | សមត្ថភាពគាំទ្រ |
| --- | --- |
| **៦.បង្កើតបណ្តាញ និងធ្វើកិច្ចសហការ ជាមួយភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការថែទាំ និងអប់រំកុមារតូច៖** សមត្ថភាពទាក់ទងនឹងការធ្វើការជាមួយអ្នកពាក់ព័ន្ធគ្រប់កម្រិត ដើម្បីសុខុមាលភាពទូទៅរបស់កុមារ | ១- សហការជាមួយគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច សម្រាប់ការចែករំលែកចំណេះដឹង ការរៀនសូត្រពីមិត្តរួមការងារ និងការគាំទ្រ។<br>២- សហការជាមួយមិត្តរួមការងារ អ្នកផ្តល់សេវាថែទាំពេលថ្ងៃ និងអ្នកអប់រំកម្រិតបឋមសិក្សា ដើម្បីធានាថាកុមារត្រូវបានអនុញ្ញាតឱ្យឡើងថ្នាក់ដោយរលូននិងប្រកបដោយការគាំទ្រដែលមានភាពសមស្របតាមការអភិវឌ្ឍនៅតាមកម្រិតផ្សេងៗគ្នារបស់ពួកគេ។<br>៣- សហការជាមួយគ្រូកម្រិតបឋមសិក្សាជាពិសេសគ្រូបង្រៀនថ្នាក់ដំបូង (ថ្នាក់ទី១) ដើម្បីយល់ច្បាស់អំពីកម្មវិធីសិក្សា និងព័ត៌មានបឋមពាក់ព័ន្ធដើម្បីធានាបាននូវការឡើងថ្នាក់ពីកម្រិតមត្តេយ្យទៅបឋមសិក្សាដោយរលូន។<br>៤- សហការជាមួយអ្នកឯកទេស និងអាជ្ញាធរពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពសមស្រប ដើម្បីកែលំអការដាក់បញ្ចូលកុមារដែលមានតម្រូវការពិសេស។<br>៥- បង្កើតកិច្ចសហប្រតិបត្តិការនិងរក្សាទំនាក់ទំនងជាមួយតួរអង្គ ឬអ្នកផ្តល់សេវាដែលពាក់ព័ន្ធ (ឧទាហរណ៍សហគមន៍ រដ្ឋាភិបាល វិស័យឯកជននិងដៃគូអភិវឌ្ឍន៍) ដើម្បីអនុវត្តសកម្មភាពសមស្រប និងធានាបាននូវការផ្តល់ការថែទាំសុខភាព អាហារូបត្ថម្ភ សុវត្ថិភាព ការការពារ និងសេវាកម្មសង្គមសម្រាប់កុមារ។<br>៦- ជួយឱ្យសមាជិកសហគមន៍ចូលរួម ដើម្បីបង្កើនបទពិសោធន៍ការរៀនសូត្ររបស់កុមារ និងលើកកម្ពស់ការថែទាំ និងអប់រំកុមារតូចនៅក្នុងសហគមន៍។<br>៧- កំណត់ និងចូលរួមជាមួយភ្នាក់ងារ ឬស្ថាប័ននៅថ្នាក់មូលដ្ឋាន ជាតិ តំបន់ និងអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីរៀនសូត្រគំរូល្អៗ អភិវឌ្ឍ និងកែច្នៃកម្មវិធីថែទាំ និងអប់រំកុមារតូចឱ្យកាន់តែប្រសើរជាងមុន។<br>៨- ដើរតួជាអ្នកតស៊ូមតិលើកទឹកចិត្តដល់អ្នកដឹកនាំសហគមន៍ ភ្នាក់ងាររដ្ឋនៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីលើកកម្ពស់ និង គាំទ្រដល់ក្រុមគោលដៅផ្នែកថែទាំ និងអប់រំកុមារតូច។<br>៩- ប្រមូលការគាំទ្រពីអ្នកពាក់ព័ន្ធផ្សេងៗ ដែលធ្វើការងារផ្នែកថែទាំ និងអប់រំកុមារតូច។ |

## ការអភិវឌ្ឍវិជ្ជាជីវៈ

ចំណុចសំខាន់ដូចគ្នាបន្ថែមទៀត គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលមានសមត្ថភាពអាចបង្ហាញអំពីការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍខ្លួនឯងនិងការអនុវត្តវិជ្ជាជីវៈជាប់ជានិច្ច ក្នុងនាមជាអ្នកធ្វើកិច្ចការផ្នែកថែទាំ និងអប់រំកុមារតូច។ ចំណុចនេះសំដៅដល់ការចូលរួមវគ្គបណ្តុះបណ្តាលវិក្រឹត្យការ ឬការបង្កើនកម្រិតវិញ្ញាបនបត្រនៃការសិក្សាផងដែរ។ គន្លឹះនៃសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចអាស្រ័យលើការប្តេជ្ញាចិត្តក្នុងការធ្វើខ្លួនឯងឱ្យសកម្ម បន្តរៀនសូត្រជាប់ជាប្រចាំពេញមួយជីវិត និងអភិវឌ្ឍជំនាញផ្ទាល់ខ្លួនឱ្យកាន់តែប្រសើរឡើង។ វាក៏ត្រូវរួមបញ្ចូលនូវសមត្ថភាពគាំទ្រច្រើនប្រភេទដែលធ្វើឱ្យគ្រូបង្រៀនអាចទទួលបានការកោតសរសើរ មានការប្តេជ្ញាចិត្តក្នុងតួនាទីជាគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចត្រូវប្រកាន់ភ្ជាប់នូវស្តង់ដារសីលធម៌វិជ្ជាជីវៈនិងឥរិយាបទការងារ និងអាចធ្វើផែនការ ចូលរួម និងត្រួតពិនិត្យខ្លួនឯងជាប់ជាប្រចាំ ដើម្បីកែប្រែការអនុវត្តការថែទាំ និងអប់រំកុមារតូចឱ្យកាន់តែប្រសើរឡើង។

ស្ថិតនៅក្នុងបរិយាកាសដែលមានការប្រែប្រួលឥតឈប់ឈរ គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ត្រូវបានគេរំពឹងថានឹងធ្វើជាបណ្តាញភ្ជាប់ទំនាក់ទំនង និងចូលរួមពាក់ព័ន្ធក្នុងការអនុវត្តជាមួយសហគមន៍ ដែលនឹងអនុញ្ញាតឱ្យពួកគេចែករំលែកបទពិសោធន៍ជាបន្តបន្ទាប់ និងរៀនពីគ្នាទៅវិញទៅមក។ នេះក៏នឹងផ្តល់ឱ្យពួកគេនូវឱកាសដើម្បីចែករំលែកអំពីរបៀបដែលពួកគេបាននឹងកំពុងប្រើប្រាស់ក្របខ័ណ្ឌសមត្ថភាពនេះ និងថាតើវាអាចត្រូវបានធ្វើឱ្យប្រសើរឡើងយ៉ាងដូចម្តេចនាពេលអនាគត ដោយផ្អែកលើការអនុវត្តដែលមានការវិវត្តនៃវិជ្ជាជីវៈនៃការថែទាំ និងអប់រំកុមារតូច ។



© Shutterstock/Anutr Yossundara

ប្រអប់ទី៤. សមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចក្នុងផ្នែកអភិវឌ្ឍវិជ្ជាជីវៈ។

| សមត្ថភាពទូទៅ/ស្នូល | សមត្ថភាពគាំទ្រឬជំរុញ |
| --- | --- |
| **៧.ធានានូវការរីកចម្រើន និងការអភិវឌ្ឍវិជ្ជាជីវៈនិងបន្តការអភិវឌ្ឍជំនាញវិជ្ជាជីវៈបុគ្គលៈ** សមត្ថភាពដែលបង្ហាញអំពីការប្ដេជ្ញាចិត្តរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ក្នុងការអភិវឌ្ឍខ្លួន និងធ្វើឱ្យប្រសើរឡើងនូវការប្រតិបត្តិវិជ្ជាជីវៈរបស់ពួកគេក្នុងនាមជាអ្នកប្រតិបត្តិការអប់រំកុមារតូច។ | ១- មានមោទនភាព និងប្ដេជ្ញាចិត្តចំពោះតួនាទីរបស់ខ្លួនក្នុងនាមជាគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។<br>២- មានអាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ និងមានក្រមសីលធម៌ រួមមានការគោរពទស្សនៈនិងវប្បធម៌ចម្រុះ ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌និងគុណតម្លៃ និងកិច្ចសហការជាមួយសហការីដូចដែលបាន កំណត់នៅក្នុងច្បាប់ជាតិ គោលនយោបាយជាតិ និងបទដ្ឋានវិជ្ជាជីវៈនិងក្រមសីលធម៌ដែលពាក់ព័ន្ធនឹងកុមារតូច។<br>៣- កំណត់ ធ្វើផែនការ និងចូលរួមក្នុងកម្មវិធី ឬសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈដែលលើកកម្ពស់ការអភិវឌ្ឍខ្លួនជាបន្តបន្ទាប់ ក្នុងនាមជាគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ។<br>៤- អភិវឌ្ឍជំនាញទំនាក់ទំនងអន្តរបុគ្គលរបស់ខ្លួន។<br>៥- បង្កើតចំណេះដឹង និងជំនាញបច្ចេកវិទ្យារបស់ខ្លួន ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីថែទាំ និងអប់រំកុមារតូច។<br>៦- ឆ្លុះបញ្ចាំងជាប្រចាំលើវិធីសាស្ត្រនានា ដើម្បីកែលម្អការអនុវត្តការថែទាំនិងអប់រំកុមារតូចដោយការអនុវត្តចំណេះដឹង ការរៀន និងការយល់ដឹងថ្មីៗពីសកម្មភាព ឬកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈក្នុងការអនុវត្តការថែទាំ និងអប់រំកុមារតូច។<br>៧- បង្ហាញភាពជាអ្នកដឹកនាំក្នុងការអនុវត្តការអប់រំកុមារតូច។<br>៨- ចែករំលែកនិងផ្សព្វផ្សាយចំណេះដឹង និងជំនាញថ្មីៗ ដែលទទួលបានពីសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈជាមួយអ្នកពាក់ព័ន្ធការអប់រំកុមារតូចតាមរយៈការជ្រើសយកទីតាំងសមស្របដូចជាកន្លែងប្រជុំ សិក្ខាសាលាជាដើម។<br>៩- ចូលរួមក្នុងសកម្មភាពស្រាវជ្រាវដើម្បីកែលម្អការថែទាំនិងការអប់រំកុមារតូច។ |

## សេចក្ដីសង្ខេប

ជ្រុងទាំងបួនរួមមានខ្លឹមសារចំណេះដឹង ឬចំណេះដឹងមុខវិជ្ជា ការប្រតិបត្តិនិងការវាយតម្លៃគរុកោសល្យ បរិយាកាសសិក្សា ការភ្ជាប់បណ្ដាញទំនាក់ទំនងនិងសហការប្រតិបត្តិការ និងការអភិវឌ្ឍវិជ្ជាជីវៈ គឺជាធាតុផ្សំគន្លឹះនៃក្របខ័ណ្ឌសមត្ថភាពសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនៅអាស៊ីអាគ្នេយ៍។ ធាតុទាំងនេះមិនស្ថិតនៅដាច់ដោយឡែកពីគ្នានោះទេ ផ្ទុយទៅវិញធាតុទាំងនេះត្រូវមានការប្រទាក់ក្រឡាបញ្ចូលគ្នានិងមានទំនាក់ទំនងគ្នាទៅវិញទៅមកនៅក្នុងសំណុំនៃសមត្ថភាពនីមួយៗ។ សមត្ថភាពដែលត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌខាងលើនេះ បង្ហាញថាតួអង្គផ្សេងៗគ្នានៅក្នុងប្រព័ន្ធមីក្រូ (ឧទាហរណ៍ ដូចជាឪពុកម្ដាយជាមួយគ្រូ គ្រូជាមួយមិត្តរួមការងារ គ្រូជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតមានអន្តរកម្មជាមួយគ្នាទៅវិញទៅមក)។

ឧទាហរណ៍ការយល់ដឹងរបស់គ្រូអំពីការអភិវឌ្ឍគ្រប់ផ្នែកនិងការសិក្សារបស់កុមារ ត្រូវបានកំណត់ថាជាសមត្ថ

ភាពស្នូលទីមួយរបស់ពួកគាត់ដែលគួរត្រូវបានប្រែក្លាយទៅជាវិធីសាស្ត្រក្នុងការរៀបចំមេរៀន និងការបង្រៀនដែលមានឥទ្ធិពលលើការសិក្សារបស់សិស្ស និងគួរប្រែក្លាយទៅជារបៀបដែលគ្រូត្រូវចូលរួមជាមួយអ្នកពាក់ព័ន្ធដទៃទៀតក្នុងកិច្ចការអប់រំកុមារតូច ដើម្បីជួយឱ្យកុមារមានការចូលរួមក្នុងដំណើរការសិក្សារៀនសូត្រ។ ស្របពេលជាមួយគ្នានេះដែរ ការស្គាល់អំពីតម្រូវការ និងភាពខ្វះចន្លោះឬភាពខុសគ្នាក្នុងការបង្កើតឱ្យមានបរិយាកាសសិក្សារៀនសូត្រប្រកបដោយអំណោយផល អាចជំរុញឱ្យគ្រូបង្កើនសមត្ថភាពបានជាអតិបរមាក្នុងការភ្ជាប់បណ្តាញទំនាក់ទំនង និងការសហការដើម្បីឱ្យពួកគាត់អាចលើកឡើងអំពីសេចក្តីត្រូវការទាំងនេះទៅដល់អ្នកពាក់ព័ន្ធសំខាន់ៗ នៃកិច្ចការអប់រំកុមារតូចឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ដូចគ្នានេះ ផ្នែកទាំងអស់ខាងលើក៏មានទំនាក់ទំនងទៅវិញទៅមកជាមួយធាតុផ្សំដែលជាទិដ្ឋភាពទូលំទូលាយនៃការថែទាំ និងអប់រំកុមារតូចផងដែរ។ ឧទាហរណ៍ការយល់ដឹងអំពីការអភិវឌ្ឍទូទៅ និងការសិក្សាក៏ដូចជាចំណេះដឹងស្តីពីច្បាប់និងគោលនយោបាយពាក់ព័ន្ធដែលទាក់ទងនឹងការថែទាំ និងអប់រំកុមារតូច អាចត្រូវបានចាត់បញ្ចូលជាលក្ខខ័ណ្ឌចាំបាច់នៃកម្មវិធីសិក្សា ឬបទដ្ឋានថ្នាក់ជាតិសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ បន្ទាប់មកទៀត សមត្ថភាពទាំងនេះអាចត្រូវបានបង្ហាញកាន់តែងាយស្រួលប្រសិនបើប្រព័ន្ធម៉ាក្រូផ្តល់ជាយន្តការគាំទ្រ។

## ៤ -ការប្រើប្រាស់ និងការអនុវត្តដែលអាចធ្វើបាន

ក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចតំបន់អាស៊ីអាគ្នេយ៍មិនមានន័យថាជាបទបញ្ញត្តិសម្រាប់គ្រូ ហើយក៏មិនត្រូវបានប្រើប្រាស់ដើម្បីដាក់ទណ្ឌកម្មលើគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចណាម្នាក់ ដែលមិនបានបង្ហាញសមត្ថភាពតាមការកំណត់នោះឡើយ ហើយក៏មិនមានន័យថាវាត្រូវបានប្រើប្រាស់សម្រាប់ជាការលើកទឹកចិត្តដល់គ្រូ ដែលបង្ហាញអំពីសមត្ថភាពទាំងនោះដែរ។ ដោយសារចំណេះដឹង និងជំនាញលើសមត្ថភាពពិសេសៗនឹងត្រូវបានទទួលយកកាន់តែច្រើនឡើងៗ ដូច្នេះក្របខ័ណ្ឌនេះអាចត្រូវបានប្រើប្រាស់ជាឯកសារយោងសម្រាប់អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលកំពុងបណ្តុះបណ្តាល (គរុសិស្ស) និងគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដែលកំពុងបម្រើការងារ ឬសម្រាប់ពង្រឹងជំនាញនិងចំណេះដឹងដែលមានស្រាប់របស់ពួកគេ។ គ្រូបង្រៀនដែលកំពុងបម្រើការងារ ក៏អាចប្រើប្រាស់ក្របខ័ណ្ឌនេះជាឯកសារយោង ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ពួកគេ និងដើម្បីតាមដាន រៀបចំផែនការក្នុងការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួន ព្រមទាំងពង្រឹងគោលដៅអាជីពរបស់ពួកគេផងដែរ។

ក្រសួងពាក់ព័ន្ធ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងសហគមន៍ដែលជាម្ចាស់ជំនួយ អាចប្រើប្រាស់ក្របខ័ណ្ឌនេះដើម្បីធ្វើឱ្យប្រសើរឡើង ឬផ្តល់អាទិភាពដល់តំបន់គោលដៅសម្រាប់ការបណ្តុះបណ្តាលដែលពួកគេចង់ផ្តោតទៅលើ។ ឧទាហរណ៍ នៅក្នុងតំបន់ភូមិសាស្ត្រដែលងាយរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ អាជ្ញាធរពាក់ព័ន្ធអាចសម្រេចចិត្តផ្តល់អាទិភាពលើការបណ្តុះបណ្តាលគ្រូដោយផ្តោតលើសមត្ថភាពដែលពាក់ព័ន្ធក្នុងការផ្តល់នូវបរិស្ថានប្រកបដោយសុវត្ថិភាព និងអំណោយផលសម្រាប់ការថែទាំ និងអប់រំកុមារតូច។ ក្នុងករណីដែលមានគ្រួសាររបស់ប្រជាពលរដ្ឋ និងសមាជិកគ្រួសារផ្សេងទៀតមិនចូលរួមក្នុងសកម្មភាពថែទាំ និងអប់រំកុមារតូច អាជ្ញាធរក៏អាចសម្រេចចិត្តផ្តល់វគ្គបណ្តុះបណ្តាលដែលមានគោលបំណងពង្រឹងសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ក្នុងការភ្ជាប់ទំនាក់ទំនងគ្រួសារទាំងនោះជាដៃគូនៅក្នុងសកម្មភាពអបរំ និងថែទាំកុមារតូច។

នៅពេលមានការយល់ព្រមពីបណ្តាប្រទេសជាសមាជិកស៊ីមេអូ (SEAMEO) ក្របខ័ណ្ឌនេះក៏ជាឯកសារដែលមានការឆ្លើយតបដ៏មានសក្តានុពលផងដែរសម្រាប់បង្ហាញផ្លូវដល់មជ្ឈមណ្ឌល SEAMEO CECCEP ដែលទើបត្រូវបានបង្កើតថ្មីសម្រាប់កិច្ចការអប់រំ ថែទាំ និងចិញ្ចឹមកុមារតូច ដែលមានទីតាំងនៅទីក្រុង Bandung ប្រទេសឥណ្ឌូណេស៊ី ក្នុងការង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំរបស់ខ្លួន។ ឯកសារក្របខ័ណ្ឌនេះ ព្រមទាំងការសិក្សាស្រាវជ្រាវលើកិច្ចការថែទាំ និងអប់រំកុមារតូច នៅអនុតំបន់ ដែលអាចផ្តល់ឱ្យក្រុមការងាររបស់មជ្ឈមណ្ឌល SEAMEO CECCEP នូវការស្វែងយល់កាន់តែស៊ីជម្រៅអំពីបញ្ហា និងតថភាពលើការថែទាំ និងអប់រំកុមារតូចក្នុងតំបន់ ស្របពេលជាមួយគ្នានេះដែរ ក្រុមការងារបានផ្តោតលើការបង្កើតកម្មវិធីកសាងសមត្ថភាព គំនិតផ្តួចផ្តើមស្រាវជ្រាវ ការតស៊ូមតិគោលនយោបាយ និងសកម្មភាពផ្សព្វផ្សាយចំណេះដឹងដែលត្រូវបានរៀបចំឡើងដើម្បីពង្រឹងកិច្ចការថែទាំ និងអប់រំកុមារតូចនៅតំបន់អាស៊ីអាគ្នេយ៍។

ភាពសាមញ្ញ និងភាពបត់បែននៃក្របខ័ណ្ឌសមត្ថភាពនេះ ផ្តល់ជូនដល់អ្នកពាក់ព័ន្ធផ្សេងៗគ្នាផ្នែកថែទាំ និងអប់រំកុមារតូច នូវមធ្យោបាយមួយ ដើម្បីយកក្របខ័ណ្ឌនេះជាឯកសារយោងក្នុងការប្រើប្រាស់ ស្របតាមបរិបទដែលពាក់ព័ន្ធ និងតម្រូវការរបស់ពួកគេរៀងៗខ្លួន។ អ្នកប្រើប្រាស់ក្របខ័ណ្ឌនេះត្រូវបានលើកទឹកចិត្តឱ្យមានភាពច្នៃប្រឌិតក្នុងការប្រើប្រាស់ដោយប្រយ័ត្នប្រយែងដើម្បីឱ្យក្របខ័ណ្ឌនេះមានសារៈសំខាន់ក្នុងការសម្រេចគោលដៅថែទាំ និងអប់រំកុមារតូច។ តារាងទី២ បង្ហាញអំពីគំរូនៃរបៀបដែលអ្នកប្រើប្រាស់ខុសៗគ្នាអាចអនុវត្តក្របខ័ណ្ឌនេះដោយផ្អែកលើគោលបំណងជាក់លាក់។

តារាងទី២ គំរូនៃការប្រើប្រាស់ និងការអនុវត្តក្របខ័ណ្ឌសមត្ថភាពថែទាំ និងអប់រំកុមារតូច

| អ្នកអនុវត្តបង្គោល | ការអនុវត្តដែលធ្វើបាន | គោលបំណង |
|---|---|---|
| ក្រសួងអប់រំ | ១. ក្រសួងអប់រំអាចយោងទៅលើក្របខ័ណ្ឌនេះដើម្បីទុកជាមូលដ្ឋាននៃការអភិវឌ្ឍស្តង់ដារសមត្ថភាពថ្មីឬពិនិត្យមើលក្របខ័ណ្ឌសមត្ថភាពគ្រូ ឬប្រព័ន្ធបញ្ជាក់សញ្ញាបត្រ ឬប្រព័ន្ធទទួលស្គាល់គុណភាពនៃប្រទេសរបស់ខ្លួន។<br>២. ក្រសួងអប់រំដែលធ្វើការលើផ្នែកថែទាំ និងអប់រំកុមារតូច អាចរៀបចំផែនការអភិវឌ្ឍន៍ ឬលើកកម្ពស់កម្មវិធីពង្រឹងសមត្ថភាពដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូក្របខ័ណ្ឌ។ | • រៀបចំផែនការសម្រាប់កម្មវិធីដែលគាំទ្រដោយថវិការដ្ឋលើការអភិវឌ្ឍសមត្ថភាពផ្នែកថែទាំ និងអប់រំកុមារតូច ។<br>• បង្កើតក្របខ័ណ្ឌសមត្ថភាពថ្មី ឬពិនិត្យកែសម្រួលក្របខ័ណ្ឌសមត្ថភាពដែលមានស្រាប់ដោយរៀនសូត្រស្វែងយល់ពីស្តង់ដារសមត្ថភាពនេះ។<br>• ពិនិត្យកែសម្រួលឡើងវិញនូវគោលនយោបាយគ្រូបង្រៀន ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនិងលក្ខខ័ណ្ឌការងាររបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ |
| ក្រសួងស្ថាប័នរដ្ឋផ្សេងទៀត (ឧ.ក្រសួងសុខុមាលភាពសង្គម ក្រសួងកិច្ចការនារី យុវជន និងកុមារ។ ល។) | ១. ភ្នាក់ងារផ្សេងទៀតរបស់រដ្ឋ ដែលធ្វើការងារផ្នែកអប់រំ និងថែទាំកុមារតូច អាចយោងក្របខ័ណ្ឌសមត្ថភាពនេះដើម្បីធ្វើផែនការសកម្មភាពពាក់ព័ន្ធលើការផ្តល់សេវាផ្សេងៗផ្នែកថែទាំ និងអប់រំកុមារតូច។ | • រៀបចំផែនការគំនិតផ្តួចផ្តើមទាំងឡាយណាដែលគាំទ្រលើផ្នែកថែទាំ និងអប់រំកុមារតូច។<br>• ពង្រឹងកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាលលើផ្នែកថែទាំ និងអប់រំកុមារ។ |
| គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | ១. អ្នករៀបចំកម្មវិធីសិក្សានៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនអាចយោងក្របខ័ណ្ឌនេះ ដើម្បីបង្កើតកម្មវិធី ឬវគ្គបណ្តុះបណ្តាលថ្មីៗស្តីពីការថែទាំ និងអប់រំកុមារតូច ឬធ្វើឱ្យប្រសើរឡើងនូវកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចពីកម្រិតឱប្លូមា ឬវិញ្ញាបនបត្រដល់កម្រិតសញ្ញាបត្រ។<br>២. អ្នករៀបចំកម្មវិធីសិក្សា អាចយោងក្របខ័ណ្ឌនេះដើម្បីលើកកម្ពស់កម្មវិធីសិក្សាដែលមានស្រាប់ស្តីពីការផ្តល់ជូនកម្មវិធីថែទាំ និងអប់រំកុមារតូច។ | • អភិវឌ្ឍកម្មវិសិក្សាថ្មីឬកែសម្រួលកម្មវិធីសិក្សាចាស់ឱ្យកាន់តែប្រសើរឡើង។<br>• បង្កើនកម្រិតនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ |

| អ្នកអនុវត្តបង្គោល | ការអនុវត្តដែលធ្វើបាន | គោលបំណង |
|---|---|---|
| មហាវិទ្យាល័យនៅគ្រឹះស្ថានឧត្តមសិក្សា | ១. មហាវិទ្យាល័យដែលមានកម្មវិធីបង្រៀន ឬវគ្គបណ្តុះបណ្តាលជំនាញថែទាំ និងអប់រំកុមារ អាចប្រើប្រាស់ក្របខ័ណ្ឌនេះជាឯកសារបង្ហាញផ្លូវ ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលថ្មី ឬកែប្រែវគ្គសិក្សាស្តីពីការថែទាំ និងអប់រំកុមារតូចដែលមានស្រាប់ឱ្យកាន់តែប្រសើរឡើយ។<br>២. មហាវិទ្យាល័យអាចយោងលើក្របខ័ណ្ឌនេះសម្រាប់បញ្ចូលវគ្គសិក្សាដែលពាក់ព័ន្ធ ក្រៅពីជំនាញថែទាំ និងអប់រំកុមារតូច និងផ្តល់ជម្រើសអាជីពក្នុងការក្លាយជាគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ដើម្បីបង្កើនចំនួនគ្រូដែលមានសមត្ថភាព។<br>៣. មហាវិទ្យាល័យនៅគ្រឹះស្ថានឧត្តមសិក្សាអាចធ្វើការសិក្សាស្រាវជ្រាវលើក្របខ័ណ្ឌនេះ និងប្រធានបទផ្សេងៗដែលពាក់ព័ន្ធនឹងការថែទាំ និងអប់រំកុមារតូច។<br>៤. មហាវិទ្យាល័យនៅគ្រឹះស្ថានឧត្តមសិក្សាអាចប្រើប្រាស់ក្របខ័ណ្ឌនេះ ជាមូលដ្ឋានក្នុងការវាយតម្លៃសមត្ថភាពផ្នែកថែទាំ និងអប់រំកុមារតូច។ | • ការពង្រឹង និងអភិវឌ្ឍវគ្គសិក្សាថែទាំ និងអប់រំកុមារតូច<br>• ឈានទៅមុខដើម្បីឆ្ពោះទៅរកការស្រាវជ្រាវលើប្រធានបទការអភិវឌ្ឍសមត្ថភាព ការអភិវឌ្ឍវិជ្ជាជីវៈនិងប្រធានបទពាក់ព័ន្ធផ្សេងទៀត |

| | | |
|---|---|---|
| នាយកមជ្ឈមណ្ឌល ឬអ្នកគ្រប់គ្រងកិច្ចការថែទាំ និងអប់រំកុមារតូច | ១. នាយកមជ្ឈមណ្ឌល ឬអ្នកគ្រប់គ្រងកិច្ចការអប់រំ និងថែទាំកុមារតូច អាចយោងលើក្របខ័ណ្ឌនេះដើម្បីអភិវឌ្ឍ ឬពង្រឹងស្តង់ដារតម្រូវដែលមានស្រាប់ និងលក្ខខ័ណ្ឌការងាររបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។<br>២. នាយកមជ្ឈមណ្ឌល ឬអ្នកគ្រប់គ្រងកិច្ចការអប់រំ និងថែទាំកុមារតូចអាចយោងលើក្របខ័ណ្ឌនេះ ដើម្បីធ្វើផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនផ្នែកអប់រំ និងថែទាំកុមារតូច។<br>៣. នាយកមជ្ឈមណ្ឌល ឬអ្នកគ្រប់គ្រងកិច្ចការអប់រំ និងថែទាំកុមារតូចអាចយោងលើក្របខ័ណ្ឌនេះដើម្បីធ្វើជាឧបករណ៍ក្នុងការតស៊ូមតិរកការគាំទ្រ និងឧបត្ថម្ភធនធានលើកិច្ចការថែទាំ និងអប់រំកុមារតូចពីរដ្ឋ សហគមន៍ និងដៃគូផ្សេងៗ។<br>៤. នាយកមជ្ឈមណ្ឌល ឬអ្នកគ្រប់គ្រងកិច្ចការអប់រំ និងថែទាំកុមារតូចអាចប្រើប្រាស់ក្របខ័ណ្ឌនេះ ដើម្បីជាធាតុចូលក្នុងការបង្រៀន ណែនាំ និងត្រួតពិនិត្យការបង្រៀនរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ | • ធ្វើឱ្យប្រសើរឡើង ឬអភិវឌ្ឍស្តង់ដារជ្រើសរើស<br>• បន្តការអភិវឌ្ឍវិជ្ជាជីវៈជាប់ជាប្រចាំ<br>• កៀរគរធនធាន<br>• បង្រៀន ណែនាំ និងត្រួតពិនិត្យការបង្រៀន |

| អ្នកអនុវត្តបង្គោល | ការអនុវត្តដែលធ្វើបាន | គោលបំណង |
|---|---|---|
| គ្រូដឹកនាំ ឬគ្រូណែនាំ ឬអ្នកប្រឹក្សាគរុកោសល្យរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច | ១. គ្រូណែនាំ ឬគ្រូដឹកនាំអាចយោងទៅលើក្របខ័ណ្ឌសមត្ថភាពនេះសម្រាប់ជ្រើសរើសគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចដែលមានសមត្ថភាព។<br>២. គ្រូណែនាំ ឬគ្រូដឹកនាំអាចប្រើក្របខ័ណ្ឌសមត្ថភាពនេះដើម្បីរៀបចំគម្រោងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។<br>៣. គ្រូណែនាំ ឬគ្រូដឹកនាំ ឬអ្នកប្រឹក្សាគរុកោសល្យអាចប្រើក្របខ័ណ្ឌសមត្ថភាពនេះជាឧបករណ៍ដើម្បីធ្វើផែនការ ត្រួតពិនិត្យ និងវាយតម្លៃការលទ្ធផលការងារក្នុងថ្នាក់រៀនរបស់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ | • ធ្វើឱ្យប្រសើរឡើង ឬអភិវឌ្ឍស្តង់ដារជ្រើសរើស<br>• រៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈ<br>• រៀបចំផែនការ និងត្រួតពិនិត្យលទ្ធផលការងាររបស់គ្រូបង្រៀន<br>• បង្វឹក និងប្រឹក្សាយោបល់ |

| | | |
|---|---|---|
| | ៤. គ្រូណែនាំ ឬគ្រូដឹកនាំ ឬអ្នកប្រឹក្សាគរុកោសល្យអាចប្រើក្របខ័ណ្ឌសមត្ថភាពនេះក្នុងការផលិតសកម្មភាពណែនាំដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច ។ | |
| គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច | ១. នៅពេលចាប់ផ្តើមឆ្នាំសិក្សានីមួយៗ គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចអាចប្រើក្របខ័ណ្ឌសមត្ថភាពនេះក្នុងការកំណត់ប្រភេទសមត្ថភាពដែលពួកគេត្រូវការ ដើម្បីបង្ហាញពេញមួយឆ្នាំសិក្សា និងមានផែនការអភិវឌ្ឍប្រភេទនៃសមត្ថភាពឱ្យសមស្របនឹងកម្មវិធីសិក្សារបស់មជ្ឈមណ្ឌល ឬសាលាថែទាំ និងអប់រំកុមារតូច។<br>២. នៅពេលចាប់ផ្តើមឆ្នាំសិក្សានីមួយៗ គ្រូអាចប្រើក្របខ័ណ្ឌសមត្ថភាពនេះដើម្បីវាយតម្លៃប្រភេទសមត្ថភាពដែលពួកគេត្រូវការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។<br>៣. ពេញមួយឆ្នាំសិក្សា គ្រូអាចយោងក្របខ័ណ្ឌសមត្ថភាពនេះដើម្បីវាយតម្លៃវឌ្ឍនភាពនៃការសម្រេចគោលដៅអភិវឌ្ឍខ្លួនដែលបានគ្រោងទុក។ | • បន្តការអភិវឌ្ឍវិជ្ជាជីវៈជាប់ជាប្រចាំ<br>• ពង្រឹងជំនាញ ចំណេះដឹង និងផ្នែកផ្សេងទៀត ឱ្យកាន់តែប្រសើរឡើង<br>• វាយតម្លៃវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍខ្លួនឯង |
| មជ្ឈមណ្ឌលអប់រំ និងថែទាំកុមារតូច<br>ឧ .មជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការថែទាំ អប់រំកុមារតូច និងចិញ្ចឹមបីបាច់<br>( SEAMEO CECCEP ) | ១. មជ្ឈមណ្ឌល SEAMEO CECCEP ឬអង្គការផ្សេងទៀតដែលធ្វើកិច្ចការថែទាំ និងអប់រំកុមារតូចក្នុងតំបន់អាចប្រើក្របខ័ណ្ឌសមត្ថភាពនេះដើម្បីរៀបចំកម្មវិធីកសាងសមត្ថភាពដល់អ្នកប្រតិបត្តិអប់រំ និងថែទាំកុមារតូចនៅក្នុងតំបន់។<br>២. អង្គការក្នុងតំបន់អាចរៀបចំ និងធ្វើសកម្មភាពស្រាវជ្រាវនិងផ្សព្វផ្សាយចំណេះដឹងទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈ និងសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច។ | • ណែនាំការអភិវឌ្ឍកម្មវិធីកសាងសមត្ថភាព<br>• ផ្តល់វេទិកាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការស្រាវជ្រាវកម្រិតតំបន់ |

## ៥. ទិសដៅបន្ត

ការបង្កើតក្របខ័ណ្ឌសមត្ថភាពនេះ ឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបានលើកឡើងក្នុងវេទិកា Putrajaya ជាពិសេសរបៀបវារៈសកម្មភាពទី៣ ដែលអំពាវនាវឱ្យមានការបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំច្បាស់លាស់សម្រាប់ការធ្វើវិជ្ជាជីវៈភាវូបនីយកម្មរបស់អ្នកធ្វើកិច្ចការផ្នែកថែទាំ និងអប់រំកុមារតូចតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈ។ ប្រសិនបើរដ្ឋមន្ត្រីអប់រំនៃប្រទេសអាស៊ីអាគ្នេយ៍ និងអ្នកពាក់ព័ន្ធសំខាន់ៗដែលធ្វើកិច្ចការថែទាំ និងអប់រំកុមារតូច អនុវត្តតាមក្របខ័ណ្ឌសមត្ថភាពសម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនេះ វាជាការបោះជំហានឆ្ពោះទៅមុខមួយទៀតដែលបង្ហាញអំពីការប្តេជ្ញាចិត្តឈានទៅរកការសម្រេចបាននូវគុណភាពគ្រូ និងការត្រៀមខ្លួនរួចរាល់សម្រាប់ការអប់រំកម្រិតបឋមសិក្សាដែលគួរត្រូវបានលើកកម្ពស់។

ដោយមានការទទួលស្គាល់មុខងារដ៏សំខាន់នៃអ្នកជំនាញដែលបានបណ្តុះបណ្តាលយ៉ាងល្អថា មានតួនាទីក្នុងការកែលម្អ និងធានាគុណភាពនៃការថែទាំ និងអប់រំកុមារតូច ទើបក្របខ័ណ្ឌនេះបានផ្តល់នូវចំណុចចាប់ផ្តើមយ៉ាងច្បាស់លាស់មួយ ប៉ុន្តែអាចបត់បែនបាន ដើម្បីបំពេញឱ្យមានភាពប្រទាក់ក្រឡាជាមួយគំនិតផ្តួចផ្តើមនានាដែលមានស្រាប់នៅថ្នាក់ជាតិ និងថ្នាក់តំបន់ដែលជាប់ទាក់ទងនឹងបទប្បញ្ញត្តិ ស្តង់ដារនិងក្របខ័ណ្ឌសមត្ថភាពសម្រាប់គ្រូ។ ផ្អែកលើបរិបទ និងស្ថានភាពនៃការថែទាំ និងអប់រំកុមារតូចក្នុងប្រទេសតំបន់អាស៊ីអាគ្នេយ៍នីមួយៗ មធ្យោបាយជាក់លាក់មួយដែលអាចធ្វើទៅបានសម្រាប់អ្នកពាក់ព័ន្ធផ្នែកថែទាំ និងអប់រំកុមារតូច គឺត្រូវវាយតម្លៃលើប្រព័ន្ធ និងគំនិតផ្តួចផ្តើមនានានៃការថែទាំ និងអប់រំកុមារតូច ត្រូវពិនិត្យមើលក្របខ័ណ្ឌសមត្ថភាពនេះ និងកំណត់ឱ្យបានថាតើពួកគេអាចទទួលយក និងអនុវត្តក្របខ័ណ្ឌសមត្ថភាពយ៉ាងដូចម្តេច ដើម្បីធ្វើឱ្យការងាររបស់ពួកគេមានការទាក់ទងកាន់តែច្រើនទៅនឹងកិច្ចការថែទាំ និងអប់រំកុមារតូច។



© *Shutterstock/aulaphoto*

# ឯកសារយោង


Asian Development Bank. (2010). Special Report: The rise of Asia's middle class. Retrieved from: https://www.adb.org/sites/default/files/publication/27726/ki2010-special-chapter.pdf

Bronfenbrenner, U. (1994). Ecological models of human development. In International encyclopedia of education.(Vol. 3, 2nd Ed.) Oxford: Elsevier.

Barnett, W. Steven. (2003). Better teachers, better preschools: Student achievement linked to teacher qualifications.NIEER Preschool Policy Matters. Issue 2.

Pacific Regional Council for Early Childhood Care and Education. (2014). Pacific guidelines for the development of national quality frameworks for ECCE: Programming for ages three to five.

Reyes, Melanie M. (2008). Migration and Filipino children left behind: A literature review. Synthesis report prepared for the United Nations Children Fund. Retrieved from: https://www.unicef.org/philippines/Synthesis_StudyJuly12008.pdf

SEAMEO INNOTECH. (2015). Success competencies of Southeast Asian School Heads: A learning guide.

SEAMEO INNOTECH and ARNEC. (n.d.) Quality assurance in early childhood care and development (ECCD) in Southeast Asia. Philippines: SEAMEO INNOTECH. Retrieved from: www.seameo-innotech.org/wp-content/uploads/2014/01/PolRes_QualityAssuranceInECCD.pdf

UNESCO. (2017). A guide for ensuring inclusion and equity in education. France: UNESCO. Retrieved from: http://unesdoc.unesco.org/images/0024/002482/248254e.pdf

UNESCO. (2016). Asia-Pacific Policy Regional Forum on ECCE: Putrajaya Declaration. Retrieved from http://bangkok.unesco.org/sites/default/files/assets/ECCE/Asia-Pacific%20Regional%20Policy%20Forum%20on%20ECCE%2010-12%20September%202013/Putrajaya_Declaration_-_Final.pdf

UNESCO. (2016a) Asia-Pacific policy-makers sign Putrajaya declaration on early childhood education. Retrieved from: http://www.unesco.org/new/en/media-services/single-view/news/asia_pacific_policy_makers_sign_putrajaya_declaration_on_ear/

UNESCO. (2013). Mother tongue-based multilingual education (MTB-MLE): Lessons learned from a decade of research and practice. Retrieved from: http://bangkok.unesco.org/content/mtb-mle-mother-tongue-based- multilingual-education-lessons-learned-decade-research-and

UNESCO and SEAMEO. (2016). Southeast Asian Guidelines for Early Childhood Teacher Development and Management. Bangkok: UNESCO and SEAMEO. Retrieved from: http://unesdoc.unesco.org/images/0024/002443/244370E.pdf

UNESCO Institute for Statistics. (2017). Education indicators. Retrieved from: http://data.uis.unesco.org

UNICEF and UNESCO. (2007). A human-rights based approach to education for all. New York: UNICEF and UNESCO. Retrieved from: http://unesdoc.unesco.org/images/0015/001548/154861e.pdf

United Nations. (2015). Sustainable Development Goal 4. Retrieved from: https://sustainabledevelopment.un.org/ sdg4

United Kingdom Civil Service Commission. (2016). User Guide: The Government Statistician Group (GSG) Competency Framework. Retrieved from: https://gss.civilservice.gov.uk/wp-content/uploads/2016/03/User-Guide.pdf

# សន្ទានុក្រមនៃពាក្យគន្លឹះ និងនិយមន័យសំខាន់ៗ

| | |
|---|---|
| ការវាយតម្លៃ | នៅក្នុងបរិបទនៃក្របខ័ណ្ឌសមត្ថភាពគ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច សមត្ថភាពវាយតម្លៃសំដៅទៅលើចំណេះដឹងនៃឧបករណ៍វាយតម្លៃផ្សេងៗនៃការរៀនសូត្រ និងការអភិវឌ្ឍកុមារ យន្តការនៃការផ្តល់ព័ត៌មានត្រឡប់ និងប្រព័ន្ធនៃការប្រមូលទិន្នន័យ។ ការវាយតម្លៃជាផ្លូវការដែលគាំទ្រដល់តម្រូវការរៀនសូត្រផ្ទាល់ខ្លួនរបស់កុមារ និងសមត្ថភាពគ្រូក្នុងការកំណត់ និងឆ្លើយតបសមស្របចំពោះកុមារដែលមានតម្រូវការពិសេស (UNESCO and SEAMEO, 2016)។ |
| ការការពារកុមារ | ជាការការពារពីការរំលោភបំពាន និងការធ្វេសប្រហែសមិនយកចិត្តទុកដាក់គ្រប់ទម្រង់ ដូចជាការរំលោភបំពានលើរាងកាយ ការរំលោភផ្លូវភេទ ការប្រមាថមើលងាយដោយពាក្យសំដី ឬការរំលោភបំពានផ្លូវចិត្តជាដើម។ ការការពារនេះក៏រួមបញ្ចូលផងដែរនូវការផ្តល់ការការចិញ្ចឹមបីបាច់ប្រកបដោយវិជ្ជមាន និងការផ្តល់នូវអាហារូបត្ថម្ភនិងការថែទាំសុខភាពសមស្រប (PRC4ECCE, 2014)។ |
| សមត្ថភាព | ជាការរួមបញ្ចូលគ្នារវាងជំនាញ ចំណេះដឹង អាកប្បកិរិយា និងលក្ខណៈសម្បត្តិដែលចាំបាច់នានាសម្រាប់ការអនុវត្តការងារប្រកបដោយជោគជ័យ (SEAMEO INNOTECH, 2015)។ |
| ក្របខ័ណ្ឌសមត្ថភាព | ជាបណ្តុំសមត្ថភាពជំនាញវិជ្ជាជីវៈដែលត្រូវការជាចាំបាច់សម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច និងអាចប្រែប្រួលតាមបរិបទប្រទេស ឬតំបន់។ ក្របខ័ណ្ឌសមត្ថភាពនេះផ្តោតលើសមត្ថភាពនានាដែលត្រូវការចាំបាច់សម្រាប់គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូចនៅតំបន់អាស៊ីអាគ្នេយ៍។ |
| ការអភិវឌ្ឍកុមារ | សំដៅទៅលើការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារទាក់ទងនឹងសុខភាព និងការរីកលូតលាស់នៃរាងកាយ ការរីកចម្រើនលើផ្នែកស្មារតី-សង្គម ភាសា វប្បធម៌ ការថែទាំខ្លួនឯង និងជំនាញក្នុងការគិត (PRC4ECCE, 2014) ។ |
| ភាពសមស្របតាមការអភិវឌ្ឍ | សំដៅទៅលើសកម្មភាពទាំងឡាយណាសមស្របទៅនឹងអាយុ និងកម្រិតចំណេះដឹងរបស់កុមារ។ ជាសកម្មភាពដែលផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន និងដំណាក់កាលរីកលូតលាស់របស់កុមារ (PRC4ECCE, 2014) |
| កុមារភាព | អង្គការយូណេស្កូ អង្គការយូនីសេហ្វ និងតាមទ្រឹស្តីអន្តរជាតិភាគច្រើនកំណត់អំពីនិយមន័យនៃពាក្យកុមារភាពថាជារយៈពេលរវាងពេលកើត រហូតដល់មានអាយុ ៨ឆ្នាំ ដែលជារយៈពេលនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សបំផុតរបស់មនុស្ស។ |

| | |
|---|---|
| ការថែទាំ និងអប់រំកុមារតូច | ការថែទាំ និងអប់រំកុមារតូច (ECCE) សង្កត់ធ្ងន់លើការអភិវឌ្ឍគ្រប់ផ្នែករបស់កុមារ (ផ្នែកសង្គម ចិត្តគំនិត ការយល់ដឹង និងរាងកាយ) ដើម្បីបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការរៀនសូត្រពេញមួយជីវិត និងសុខុមាលភាព។ ដូចដែលបានបញ្ជាក់នៅក្នុងគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ការថែទាំ និងអប់រំកុមារតូចផ្តោតទៅលើការត្រៀមខ្លួនរបស់កុមារសម្រាប់ការអប់រំនៅបឋមសិក្សា។<br><br>ការអប់រំកុមារតូច (ECE) ការអប់រំ និងថែទាំកុមារតូច (ECEC) ការថែទាំកុមារតូច ការអភិវឌ្ឍកុមារតូច (ECD) និងការថែទាំ និងអភិវឌ្ឍកុមារតូច (ECCD) គឺស្ថិតនៅក្នុងចង្កោមនៃពាក្យដែលត្រូវបានប្រើជំនួសគ្នាទៅវិញទៅមក។ |
| កម្មវិធីថែទាំ និងអប់រំកុមារតូច | ជាកម្មវិធីបន្ថែមពីលើការផ្តល់កាថែទាំកុមារ និងផ្តល់ជូននូវបណ្តុំនៃសកម្មភាពសិក្សាទាំងឡាយដែលមានរចនាសម្ព័ន្ធ និងគោលបំណងច្បាស់លាស់ ទោះបីជាស្ថិតនៅក្នុងគ្រឹះស្ថានអប់រំផ្លូវការ (មត្តេយ្យសិក្សា ឬ ISCED 0) ឬជាផ្នែកមួយនៃកម្មវិធីអភិវឌ្ឍកុមារក្រៅផ្លូវការ។ ជាធម្មតា កម្មវិធីថែទាំ និងអប់រំកុមារតូច ត្រូវបានរៀបចំឡើងសម្រាប់កុមារចាប់ពីអាយុ ៣ ឆ្នាំឡើងទៅ និងបានរាប់បញ្ចូលទាំងសកម្មភាពសិក្សារៀនសូត្រដែលមានការរៀបទុកជាមុន ដោយកំណត់យកការរៀនសូត្រជាមធ្យម យ៉ាងហោចណាស់ស្មើនឹងរយៈពេល២ម៉ោងក្នុងមួយថ្ងៃ និង១០០ថ្ងៃក្នុងមួយឆ្នាំ (UNESCO and SEAMEO, 2016)។ |
| គ្រូបង្រៀនផ្នែកថែទាំ និងអប់រំកុមារតូច | បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សមរម្យដែលធ្វើការនៅក្រៅផ្ទះរបស់ខ្លួន ដើម្បីផ្តល់ការថែទាំ និងអប់រំដល់កុមារនៅកន្លែងដែលមានចុះបញ្ជីត្រឹមត្រូវ។ សម្រាប់គោលបំណងនៃក្របខ័ណ្ឌសមត្ថភាពនេះ ប្រទេសនីមួយៗចាំបាច់ត្រូវពិចារណាអំពីតួនាទីផ្សេងៗគ្នារបស់អ្នកជំនាញផ្នែកកុមារតូចក្នុងការបង្កើតនិយមន័យច្បាស់លាស់មួយតាមបរិបទនៃប្រទេសរបស់ខ្លួន។ (ដកស្រង់ពី PRC4ECCE, 2014)។ |
| បរិយាបន្ន | សំដៅលើដំណើរការនៃការជំនះឧបសគ្គដែលរារាំងដល់វត្តមាននៃការចូលរួម និងលទ្ធផលសម្រេចបានរបស់សិស្ស (UNESCO,2017)។ |
| ជំនាញអន្តរបុគ្គល | តាមការកំណត់និយមន័យដោយវចនានុក្រមអង់គ្លេស Oxford ជំនាញអន្តរបុគ្គលសំដៅលើសមត្ថភាពក្នុងការប្រាស្រ័យទាក់ទង ឬអន្តរកម្មល្អជាមួយមនុស្សផ្សេងទៀត។ |
| ជំនាញគ្រប់គ្រងខ្លួនឯង | សំដៅទៅលើជំនាញ និងការទំនាក់ទំនងដែលកើតឡើងនៅក្នុងចិត្តផ្ទាល់ខ្លួនរបស់មនុស្សណាម្នាក់ ដូចជាតាមរយៈការធ្វើសមាធិ ការអធិដ្ឋាន ការបួងសួង ចក្ខុវិស័យ និងការផ្ទៀងផ្ទាត់ជាវិជ្ជមាន។ |

| | |
|---|---|
| ការអប់រំពហុភាសាផ្អែកលើភាសាកំណើត (MTB-MLE) | ការអប់រំពហុភាសាផ្អែកលើភាសាកំណើត (MTB-MLE) សំដៅលើការប្រើប្រាស់ភាសាកំណើតជាភាសាចំបងក្នុងការបង្រៀននៅក្នុងថ្នាក់រៀន។ MTB-MLE មិនមែនជាការរឹតត្បិតការប្រើប្រាស់ភាសាជាតិ និងអន្តរជាតិណាមួយនោះទេ ប៉ុន្តែវាគឺជាការរៀបចំឱ្យបានត្រឹមត្រូវដើម្បីឱ្យកុមាររៀនភាសាទាំងនេះបានល្អ។ MTB-MLE ទទួលស្គាល់ថាការចាប់ផ្តើមប្រើភាសាដែលពួកគេស្ទាត់ជំនាញអាចជួយឱ្យកុមារបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំមួយដែលអាចឱ្យពួកគេផ្លាស់ប្តូរទៅរៀនជាភាសាជាតិឬភាសាអន្តរជាតិផ្សេងទៀតយ៉ាងមានប្រសិទ្ធភាព (UNESCO, 2013)។ |
| លទ្ធផល | ជាលទ្ធផលដែលជាទីប៉ងប្រាថ្នាសម្រាប់ការរៀនសូត្រនិងការអភិវឌ្ឍរបស់កុមារនៅលើផ្នែកផ្សេងៗគ្នា។ |
| ការអប់រំនៅកម្រិតមត្តេយ្យសិក្សា | ISCED ជាការអប់រំកម្រិតសូន្យ ការអប់រំកម្រិតមត្តេយ្យសិក្សាជាកម្មវិធីនៅដំណាក់កាលដំបូងនៃបង្ហាត់បង្រៀនដែលបានរៀបចំឡើងជាចម្បងដើម្បីណែនាំកុមារដែលមានអាយុយ៉ាងតិចចាប់ពី ៣ ឆ្នាំទៅ ឱ្យស្គាល់នូវបរិយាកាសបែបសាលារៀន និងផ្តល់ស្ពានចម្លងរវាងផ្ទះនិងសាលារៀនដល់ពួកគេ។ កម្មវិធីអប់រំមត្តេយ្យសិក្សា សំដៅលើការអប់រំកុមារតូច ការអប់រំទារកដ្ឋាន ការអប់រំមុនចូលសាលាមត្តេយ្យសិក្សា ឬការថែទាំកុមារជាដើម ដែលកម្មវិធីទាំងនេះ គឺជាសមាសធាតុនៃកម្មវិធីថែទាំ និងអប់រំកុមារតូច។ នៅពេលបញ្ចប់កម្មវិធីទាំងនេះកុមារត្រូវបន្តការសិក្សានៅកម្រិត ISCED 1 (បឋមសិក្សា)។ (UNESCO and SEAMEO, 2016)។ |
| ការអភិវឌ្ឍវិជ្ជាជីវៈ | ការអភិវឌ្ឍវិជ្ជាជីវៈ សំដៅលើប្រភេទផ្សេងៗនៃសកម្មភាពបណ្តុះបណ្តាល ការអប់រំផ្លូវការ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ដែលអាចជួយគ្រូបង្រៀន អ្នកធ្វើការរដ្ឋបាល និងអ្នកអប់រំ អាចកែប្រែនូវចំណេះដឹងវិជ្ជាជីវៈ សមត្ថភាព ជំនាញ និងប្រសិទ្ធភាពនៃការងាររបស់ពួកគេកាន់តែប្រសើរឡើង (The Glossary of Education Reform) ។ |
| ការជ្រើសរើសបុគ្គលិក | ជាដំណើរការនៃការបន្ថែមបុគ្គលថ្មីចូលទៅក្នុងស្ថាប័នមួយ (UNESCO and SEAMEO, 2016)។ |

United Nations
Educational, Scientific and
Cultural Organization

Education
Sector

With the financial support of

Malaysia
Funds-in-Trust

UNESCO Bangkok Office
Mom Luang Pin Malakul Centenary Building
920 Sukhumvit Road, Prakanong, Klongtoei
Bangkok 10110, Thailand
Email: iqe.bgk@unesco.org
Website: bangkok.unesco.org
Tel: +66-2-3910577 Fax: +66-2-3910866

SEAMEO Secretariat
Mom Luang Pin Malakul Centenary Building
920 Sukhumvit Road, Prakanong, Klongtoei
Bangkok 10110, Thailand
Email: secretariat@seameo.org
Website: www.seameo.org
Tel: +66 (0) 2391-0144 Fax: +66 (0) 2381-2587

4 QUALITY EDUCATION

Sustainable Development Goals